# យុទ្ធសាស្ត្រអប់រំឌីជីថល សម្រាប់សាលារៀន



២០២៤

ក្រសួងអប់រំ យុវជន និងកីឡា

# យុទ្ធសាស្ត្រ

# អប់រំឌីជីថលសម្រាប់សាលារៀន

មិថុនា ២០២៤

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

# អារម្ភកថា

បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិម្មិត ជាឧបករណ៍មានអានុភាពសម្រាប់ជានាការផ្លាស់ប្តូរផលិតភាព កំណើន និងវឌ្ឍនភាពក្នុងគ្រប់វិស័យ។ បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិម្មិត បង្ហាញពីឱកាសដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ ដើម្បីជានាឱ្យមានបរិវត្តកម្មនិងនវានុវត្តន៍ក្នុងវិស័យអប់រំ។

ក្នុងវិស័យអប់រំ បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិម្មិត មានឥទ្ធិពលខ្លាំងក្នុងការផ្លាស់ប្តូរទម្រង់យន្តការ រចនាសម្ព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធ។ លើសពីនេះទៀត បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិម្មិត ជួយដល់ការស្រាវជ្រាវ ការបង្រៀននិងរៀន ការវាយតម្លៃការសិក្សា ការដឹកនាំ ការគ្រប់គ្រង ការអនុវត្តកម្មវិធីសិក្សា និងការផ្លាស់ប្តូរឥរិយាបថសិស្ស។

ការរៀបចំតាក់តែងយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន សំដៅផ្តល់ភាពងាយស្រួលនិងងាយបត់បែនឱ្យសាលារៀនធ្វើជាម្ចាស់ក្នុងការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណផលការងារពោលគឺប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ សាលារៀនត្រូវមានកាតព្វកិច្ចរៀបចំផែនការសកម្មភាព និងកៀរគរធាតុចូលនិងធនធានសម្រាប់ការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ អគ្គនាយកដ្ឋាននិងនាយកដ្ឋានថ្នាក់ជាតិ ត្រូវទទួលខុសត្រូវបំពេញកាតព្វកិច្ចផ្តល់ធាតុចូល និងតាមដានរាល់ការសម្រេចគុណផលនៃការអនុវត្តយុទ្ធសាស្ត្រនេះ។

ក្រសួងអប់រំ យុវជន និងកីឡា មានជំនឿយ៉ាងមុតមាំថា ស្ថាប័នរដ្ឋ ឯកជន ដៃគូអភិវឌ្ឍ និងតួអង្គពាក់ព័ន្ធនិងមន្ត្រីនៃស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាធារណជនចូលរួម និងពង្រីកការគាំទ្រសាលារៀនក្នុងការអនុវត្តយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន សំដៅជានានូវបរិយាកាសសុវត្ថិភាព និងសន្តិសុខ សម្រាប់ការរៀន និងការបង្រៀន ប្រកប ដោយគុណភាព សមធម៌ និងបរិយាបន្ន។

ថ្ងៃ សុក្រ ៩ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

## មាតិកា

**អារម្ភកថា** ........ i
**សេចក្តីផ្តើម** ........ ១
**យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន** ........ ៩
**១. ចក្ខុវិស័យ** ........ ៩
**២. គុណតម្លៃ** ........ ៩
**៣. បេសកកម្ម** ........ ១០
**៤. លទ្ធផលអប់រំ** ........ ១០
៤.១ អ្នកសិក្សាចង់ចេះចង់ដឹង ........ ១១
៤.២ អ្នកគិតម្ចាស់ការ ........ ១២
៤.៣ ពលរដ្ឋសកល ........ ១២
៤.៤ ពលរដ្ឋឌីជីថល ........ ១៤
៤.៥ អ្នកស្រាយបញ្ហា ........ ១៤
**៥. បរិវត្តកម្មអប់រំ** ........ ១៥
៥.១ បរិវត្តកម្មទី១៖សាលាមានបរិយាកាសអំណោយផលសម្រាប់ប្រើបច្ចេកវិទ្យាឌីជីថល ១៦
៥.១.១ យុទ្ធសាស្ត្រ៖ បង្កើតបរិយាកាសសុវត្ថិភាពនិងសន្តិសុខ (តាមអ៊ីនធឺណិត) សម្រាប់ការរៀន និងការបង្រៀន ប្រកបដោយគុណភាពនិងបរិយាបន្ន ........ ១៧
៥.១.២ យុទ្ធសាស្ត្រ ៖បង្កើតបរិស្ថានឌីជីថលសម្រាប់ការរៀននិងការបង្រៀន ប្រកបដោយគុណភាពនិងបរិយាបន្ន ........ ១៩
៥.១.៣ យុទ្ធសាស្ត្រ៖ ធានាឱ្យមានភាពជាដៃគូសម្បូរបែបដើម្បីជានាសមធម៌ឌីជីថល ........ ២១
៥.២ បរិវត្តកម្មទី២៖ គ្រូបង្រៀន និងអ្នកអប់រំប្រែកាន់តួនាទីជាអ្នកលើកទឹកចិត្ត និងជាអ្នកដឹកនាំដើម្បីបង្កើតសង្គមពុទ្ធិជន ដោយប្រើបច្ចេកវិទ្យាឌីជីថល ........ ២៤
៥.២.១ យុទ្ធសាស្ត្រ៖ អភិវឌ្ឍសមត្ថភាព ទំនុកចិត្ត និងស្វ័យប្រសិទ្ធភាពរបស់អ្នកអប់រំឱ្យប្រើបច្ចេកវិទ្យាឌីជីថល ........ ២៤
៥.៣ បរិវត្តកម្មទី៣៖ នាយក/នាយិកាជាអ្នកដឹកនាំមានចក្ខុវិស័យ និងជាអ្នកស្រាយបញ្ហាដោយប្រើវិជ្ជាឌីជីថល ........ ២៧

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៥.៣.១ យុទ្ធសាស្រ្ត ៖ លើកកម្ពស់អភិបាលកិច្ចល្អរបស់សាលារៀន ដោយប្រើបំណិន និងវិជ្ជាផ្នែកបច្ចេកវិទ្យាឌីជីថល ....... ២៨
៥.៤ បរិវត្តកម្មទី៤៖ កម្មវិធីសិក្សាឌីជីថល និងធនធានគរុកោសល្យឌីជីថល ជួយដល់បរិវត្តកម្ម និងនវានុវត្តន៍នៃការរៀននិងបង្រៀន ....... ៣០
៥.៤.១ យុទ្ធសាស្រ្ត ៖ ផ្តល់ធនធានសិក្សាឌីជីថលសម្រាប់ការរៀន បង្រៀន និងការវាយតម្លៃ ....... ៣១
**៦. តារាងសូចនាករអនុវត្ត** ....... ៣៣

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឆ្ពោះទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលការអភិវឌ្ឍធនធានមនុស្សគឺជាបញ្ចកោណទី១ ផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ នៅក្នុងមុំទី១នៃបញ្ចកោណទី១ ការលើកកម្ពស់ការអប់រំឌីជីថលត្រូវបានផ្តល់អាទិភាព ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀន និងការជំរុញនូវការចាប់យកមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM)។

ផ្អែកលើអាទិភាពនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តល់អាទិភាពទៅលើបច្ចេកវិទ្យាឌីជីថល ជាមធ្យោបាយសម្រាប់ជានាការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឈានទៅសម្រេចចក្ខុវិស័យត្រឹមឆ្នាំ២០៣០ និងឆ្នាំ២០៥០ ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយមានគោលនយោបាយគាំទ្រសំខាន់ៗចំនួនបួនរួមមាន៖

- គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងក្នុងវិស័យអប់រំនៅកម្ពុជាឆ្នាំ២០០៤
- ផែនការមេសម្រាប់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងក្នុងវិស័យអប់រំឆ្នាំ២០១៣
- គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងក្នុងវិស័យអប់រំឆ្នាំ២០១៨
- ផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាអប់រំឆ្នាំ២០២២។

ទន្ទឹមនឹងនេះ ការវិវត្តន៍នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ត្រូវបានទទួលការចាប់អារម្មណ៍និងការឱ្យតម្លៃក្នុងការផ្លាស់ប្តូរបែបបទ របៀបរបបក្នុងការធ្វើការងារ ការទំនាក់ទំនង និងការទទួលបានព័ត៌មាន។ បច្ចេកវិទ្យាអប់រំ (EdTech) ត្រូវបានឱ្យនិយមន័យជាផ្នែករឹង ផ្នែកទន់ និងមាតិកាឌីជីថល និងត្រូវបានបង្កើតឡើងសម្រាប់ការគ្រប់គ្រង និងគាំទ្រការបង្រៀន ការរៀន និងការវាយតម្លៃនៅគ្រប់កម្រិត។ ប្រព័ន្ធព័ត៌មានសាលារៀន(SIS) អនុញ្ញាតឱ្យសាលារៀនគ្រប់គ្រងព័ត៌មានតាមប្រព័ន្ធឌីជីថល ដោយសម្រួលដល់កិច្ចការប្រតិបត្តិការ និងការគ្រប់គ្រងជំនួសឱ្យការងារឯកសារក្រដាស។ មុខងាររបស់ប្រព័ន្ធព័ត៌មានសាលារៀនមានតួនាទីគ្រប់គ្រងព័ត៌មានអំពីសិស្ស គ្រូ ថ្នាក់ និងការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា តារាងពេលវេលា ការតាមដានវត្តមាន របាយការណ៍ ចំណាត់ថ្នាក់ និងប្រព័ន្ធសិក្សាតាម

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អេឡិចត្រូនិកជាដើម។ ប្រទេសកម្ពុជាបច្ចុប្បន្នត្រឹមឆ្នាំ២០២៣ មានក្រុមហ៊ុនឯកជនប្រមាណ១០ បាន និងកំពុងផ្តល់សេវានៃប្រព័ន្ធព័ត៌មានសាលារៀន ដូចជា ប្រព័ន្ធរបស់ក្រសួងអប់រំ របស់ក្រុមហ៊ុន Metfone, ក្រុមហ៊ុន Poscar digital, ក្រុមហ៊ុន CAMIS Solutions, ក្រុមហ៊ុន One-click solution, ក្រុមហ៊ុន CloudNet, ក្រុមហ៊ុន CLOSO, ក្រុមហ៊ុន SALA Tech Digital Solutions។ល។ ប្រព័ន្ធគ្រប់គ្រងការរៀន (LMS) ផ្តល់ឱកាសឱ្យគ្រូផ្តល់នូវការបង្រៀន ការណែនាំការរៀន ការវាយតម្លៃ និងការផ្តល់មូលវិចារកែលម្អ។ ខ្លឹមសារនៃការសិក្សា គំនិត និងការអនុវត្តត្រូវបានបង្កើតឡើងក្នុងទម្រង់នៃកម្មវិធីសិក្សា ប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័រ។ គ្រូបង្រៀនអាចបញ្ចូលមេរៀន សម្ភារៈបង្រៀនផ្ទាល់ខ្លួន តាមតម្រូវការសម្រាប់កម្រិតថ្នាក់ មេរៀន គរុកោសល្យ និងលទ្ធផលសិក្សា ដើម្បីគាំទ្រដល់ការបង្រៀន ការរៀន និងការវាយតម្លៃការសិក្សា។ ខ្លឹមសារឆ្លើយតបនឹងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា កំពុងត្រូវបានបង្កើតឡើង។ គ្រូបង្រៀនអាចប្រើមេរៀនដែលមានស្រាប់ ក្នុងប្រព័ន្ធសម្រាប់ការរៀន ការបង្រៀន ការដឹកនាំការរៀន និងការវាយតម្លៃ ដូចជា Sala Digital, Sala Tech, E-School Cambodia, Sangapac Anuwat, TESDOPI។

ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយក្រុមការងារវិស័យអប់រំ សម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។ បើទោះបីជាសមិទ្ធផលអប់រំមានការកើនឡើងទាំងបរិមាណនិងគុណភាពយ៉ាងណាក្តី បញ្ហាប្រឈមមួយចំនួននៅតែជាកង្វល់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា។ បញ្ហាប្រឈមទាំងនោះរួមមាន៖

- **លទ្ធភាពទទួលសេវាអប់រំ**

អត្រាសិស្សចុះឈ្មោះចូលរៀននៅបឋមសិក្សាមាន៨៦.៨% នៅមធ្យមសិក្សាបឋមភូមិ ៤៣.៦% និងនៅមធ្យមសិក្សាទុតិយភូមិ២៦.៣%។ ក្នុងចំណោមសិស្សចំនួន ៤៩០,០០២នាក់ ដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី១ ក្នុងឆ្នាំសិក្សា២០០៩-២០១០ មានសិស្ស១០៤,៣៧៤នាក់ បានបញ្ចប់ការសិក្សាថ្នាក់ទី៦ សិស្ស៥២,៩៧០នាក់ បានបញ្ចប់ថ្នាក់ទី៩ និងសិស្ស២៤,៩៦៤នាក់ បានបញ្ចប់ថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០២០-២០២១[1] ។ លទ្ធផលនេះពន្យល់ច្បាស់អំពីការបាត់បង់ឱកាសរៀនរបស់សិស្ស មុនពួកគេមានសមត្ថភាពនិងលទ្ធភាពបន្តការសិក្សានៅកម្រិតឧត្តមសិក្សា។

[1] ក្រសួងអប់រំ យុវជន និងកីឡា (២០១០-២០២១) ស្ថិតិ និងសូចនាករអប់រំសាធារណៈ

- **គុណភាពអប់រំ**

លទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៣[2] ទី៦[3] និងទី៨[4] បង្ហាញពីភាពចុះអន់ថយនៃគុណភាពអប់រំតាមឆ្នាំនីមួយៗ។ ការវាយតម្លៃថ្នាក់ទី៦ ដែលធ្វើឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០២១ អំឡុងរាតត្បាតជំងឺកូវីដ-១៩ ប្រៀបធៀបនឹងការវាយតម្លៃពីមុន សម្រាប់ថ្នាក់ទី៦ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១៦ ពិន្ទុភាសាខ្មែរបានធ្លាក់ចុះពី៥២.៧% ក្នុងឆ្នាំ២០១៦ មកត្រឹម៤៦.៥%នៅឆ្នាំ២០២១។ លទ្ធផលគណិតវិទ្យាបានធ្លាក់ចុះយ៉ាងខ្លាំងពី៤៩.៤% ក្នុងឆ្នាំ២០១៦ មកត្រឹម៣៨.៣% ក្នុងឆ្នាំ២០២១។ ការវាយតម្លៃការសិក្សាកម្រិតតំបន់ SEA-PLM[5] លើសិស្សថ្នាក់ទី៥ និងការវាយតម្លៃអន្តរជាតិ PISA[6] លើសិស្សអាយុ១៥ឆ្នាំ ក៏បង្ហាញថា សិស្សកម្ពុជាចន្លោះពី១០-២០ភាគរយប៉ុណ្ណោះ ដែលមានសមត្ថភាពកម្រិតអប្បបរមាតាមកម្រិតថ្នាក់ និងអាយុរបស់ពួកគេ។ នេះមានន័យថា សិស្សានុសិស្សជាច្រើនដែលមានឱកាសសិក្សាក្នុងសាលារៀនពុំទទួលបានចំណេះដឹង និងជំនាញដូចមានចែងក្នុងស្តង់ដាកម្មវិធីសិក្សាទេ។

- **ការគ្រប់គ្រង**

ប្រព័ន្ធអប់រំកម្ពុជា ត្រូវបានកំណត់ជាលក្ខណៈមជ្ឈិមការ។ ក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ជាតិទទួលបន្ទុកលើបញ្ហាអប់រំ ដោយប្រើវិធីសាស្រ្តតាមឋានានុក្រម សម្រាប់គ្រប់គ្រង និងអភិបាលកិច្ចនៅគ្រប់កម្រិត។ នៅថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡាមានអគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យ។ នៅថ្នាក់ក្រោមជាតិ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការគ្រប់គ្រងសកម្មភាពអប់រំកម្រិតមូលដ្ឋាន ថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋាននិងនាយកដ្ឋានថ្នាក់ជាតិមួយចំនួនទទួលភារកិច្ចប្រមូលទិន្នន័យពីសាលារៀន ដើម្បីបង្កើតគោលនយោបាយ ផែនការ អនុវត្ត និងវាយតម្លៃគុណផលអប់រំ។ ដូច្នេះ គណៈគ្រប់គ្រង

---

[2] ក្រសួងអប់រំ យុវជន និងកីឡា (២០២០) សមិទ្ធផលសម្រេចបានរបស់សិស្សថ្នាក់ទី៣ : លទ្ធផលពីតេស្តវាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ ឆ្នាំ២០១៩

[3] ក្រសួងអប់រំ យុវជន និងកីឡា (២០២២) របាយការណ៍វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៦ ឆ្នាំសិក្សា ២០២០-២០២១

[4] ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) របាយការណ៍វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៨ ឆ្នាំសិក្សា ២០២១-២០២២

[5] UNICEF & SEAMEO. (2020). SEA-PLM 2019 Main Regional Report: Children's learning in 6 Southeast Asian countries. Bangkok, Thailand: United Nations Children's Fund (UNICEF) & Southeast Asian Ministers of Education Organization (SEAMEO) – SEA-PLM Secretariat

[6] OECD (2023), PISA 2022 Results (Volume I): The State of Learning and Equity in Education, PISA, OECD Publishing, Paris, https://doi.org/10.1787/53f23881-en.

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

សាលាត្រូវទទួលភារកិច្ចប្រមូលនិងរាយការណ៍ទិន្នន័យសាលាតាមវិធីរដ្ឋបាលតាមកាលកំណត់នៃឆ្នាំសិក្សា។ កិច្ចការនេះអាចជាបន្ទុកសម្រាប់សាលារៀននិងនាំឱ្យមានការពន្យារ ឬផ្តល់ទិន្នន័យមិនទាន់ពេលវេលា។

ក្រសួងអប់រំ យុវជន និងកីឡា ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធអប់រំ ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS) ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំឧត្តមសិក្សា (HEMIS) ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ (NEF-MIS) ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស(HRMIS) និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុអប់រំ (EFMS)។ នេះមានន័យថា ខណៈពេលដែលរដ្ឋបាលថ្នាក់ជាតិនៃក្រសួងអប់រំ យុវជន និងកីឡា ទទួលយកនិងទទួលស្គាល់គុណតម្លៃនៃបច្ចេកវិទ្យាឌីជីថល សាលារៀននៅតែពឹងផ្អែកខ្លាំងលើឯកសារសម្រាប់កិច្ចការរដ្ឋបាលគ្រប់ប្រភេទ ហើយកុំព្យូទ័រ និងប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំមិនត្រូវបានប្រើប្រាស់ពេញលេញនោះទេ ជាពិសេស នៅកម្រិតសាលារៀន។

- **ការអប់រំនិងគ្រូបង្រៀន**

ការខ្វះគុណវុឌ្ឍិស្របតាមកម្រិតថ្នាក់របស់គ្រូបង្រៀន ជាឧបសគ្គរាំងដល់ការលើកកម្ពស់គុណភាពនៃការរៀននិងបង្រៀន។ ស្ថិតិនិងសូចនាករអប់រំ[7] បង្ហាញថា ជាងពាក់កណ្តាលនៃគ្រូបង្រៀនចំនួន៩៤,៦៩២នាក់ មានវិញ្ញាបនបត្រកម្រិតមធ្យមសិក្សាទុតិយភូមិ ឬទាបជាង។ បញ្ហាគ្រូបង្រៀនខ្វះគុណវុឌ្ឍិជារឿងមួយ។ រឿងមួយទៀត សាលារៀនមួយចំនួនខ្វះគ្រូបង្រៀន បើគិតជាចំនួន ហើយសាលារៀនមួយចំនួន លើសចំនួនគ្រូបង្រៀន។ ដូច្នេះ ចេតនាលើកកម្ពស់គុណភាពនៃការរៀននិងបង្រៀនចាំបាច់ត្រូវដោះស្រាយបញ្ហាគុណវុឌ្ឍិគ្រូបង្រៀន ចំនួនគ្រូបង្រៀន និងការបែងចែកគ្រូបង្រៀនតាមសាលារៀនឱ្យមានប្រសិទ្ធភាព។

ក្រៅពីបញ្ហាប្រឈមដែលបានរៀបរាប់ខាងលើ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក៏ជាបញ្ហាប្រឈមដែលចម្បងនៅក្នុងវិស័យអប់រំផងដែរ ដែលបញ្ហាទាំងនោះរួមមាន៖

- ហេដ្ឋារចនាសម្ព័ន្ធ៖ សាលារៀនមានបញ្ហាការខ្វះថាមពលអគ្គិសនី អ៊ីនធឺណិត ឧបករណ៍ឆ្លាតវៃ ទូរទស្សន៍ និងវិទ្យុ ដើម្បីទទួលការផ្សាយ និងប្រើប្រាស់ធនធានឌីជីថល។
- ធនធាន៖ ក្រសួងអប់រំ យុវជន និងកីឡា ពុំមានថវិកាគ្រប់គ្រាន់ និងអ្នកជំនាញក្នុងវិស័យឌីជីថលសម្រាប់ការអប់រំ ដែលអាចជួយសាលារៀនឱ្យក្លាយជាសាលារៀនឌីជីថល។ គ្រូបង្រៀន សិស្ស និងប្រជាពលរដ្ឋពុំទាន់មានក្របខ័ណ្ឌសមត្ថភាពឌីជីថលទៅតាមកម្រិតស្តង់ដា។

---

[7] ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) ស្ថិតិ និងសូចនាករអប់រំសាធារណៈ

- សាលា/គ្រូបង្រៀនៈ នាយកសាលា អ្នកគ្រប់គ្រង និងគ្រូបង្រៀនពុំទាន់មានជំនាញ និងធនធានគ្រប់គ្រាន់ដើម្បីបញ្ចូលបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំក្នុងការគ្រប់គ្រងសាលារៀន ការរៀន ការបង្រៀន និងការវាយតម្លៃ។

- មាតាបិតា/សិស្សៈ មាតាបិតានិងសិស្សខ្វះជំនាញ និងផ្នត់គំនិតឌីជីថល ខ្វះតំណអ៊ីនធឺណិត និងឧបករណ៍បច្ចេកវិទ្យាប្រើនៅផ្ទះ និងខ្វះខ្លឹមសារមេរៀនតាមកម្មវិធីសិក្សាក្នុងប្រព័ន្ធឌីជីថល។

- អ្នកផ្តល់សេវាៈ អ្នកផ្គត់ផ្គង់សេវាបច្ចេកវិទ្យាអប់រំ និងអ្នកដែលបង្កើតមាតិកា ពុំទាន់មានសមត្ថភាពគរុកោសល្យ ដើម្បីបង្កើតមាតិកាឌីជីថលគាំទ្រការបង្រៀន ការរៀន និងការវាយតម្លៃ ជាពិសេសទាក់ទងនឹងបញ្ញាសិប្បនិម្មិត។

ដើម្បីរួមចំណែកក្នុងការជួយដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួង អប់រំ យុវជន និងកីឡាប្តេជ្ញាសម្រេចឱ្យបានអាទិភាពចំនួនប្រាំបីៈ ១) ពង្រឹងអភិបាលកិច្ចសាលារៀន, ២) ពិនិត្យនិងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពបន្ថែមក្រៅម៉ោងសិក្សា ស្របតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងអាកប្បកិរិយារបស់សិស្ស, ៣) ការថែរក្សាសុខភាពសិស្សតាមរយៈកម្មវិធីអាហារូបត្ថម្ភរបស់កុមារ និងការគ្រប់គ្រងគុណភាពអាហារតាមសាលារៀន, ៤) ជំរុញនិងលើកទឹកចិត្តឱ្យមានការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងវិស័យអប់រំ ស្របតាមពាក្យស្លោកភាពជាដៃគូ "រដ្ឋនិងសហគមន៍ដើម្បីការអប់រំ", ៥) ពង្រឹងការអប់រំឌីជីថល, ៦) ជំរុញមជ្ឈមណ្ឌលឧត្តមភាពក្នុងការអប់រំឧត្តមសិក្សា, ៧) កសាងប្រព័ន្ធនិងអភិវឌ្ឍសមត្ថភាព, និង៨) អភិវឌ្ឍការអប់រំកាយ និងកីឡា។

ក្នុងន័យនេះ ក្រសួង បានដាក់ចេញចក្ខុវិស័យផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០២៤-២០២៨) គឺជានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍប្រព័ន្ធអប់រំ និងចក្ខុវិស័យអភិវឌ្ឍជាតិៈ ប្រជាជនកម្ពុជា "មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត" ប្រកបដោយអំណត់ធន់ សហគ្រិនភាព នវានុវត្តន៍ និងសីលធម៌ប្រពៃ ដោយរដ្ឋជានាផ្តល់សេវាអប់រំជាមូលដ្ឋានសម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី៩ បំពាក់ជំនាញ និងបច្ចេកវិទ្យាដែលជាតម្រូវការទីផ្សារការងារ និងធុរកិច្ច ពង្រឹងការបណ្តុះបណ្តាល និងផ្លាស់ប្តូរជំនាញ ស្របនឹងតម្រូវការទីផ្សារការងារ ពង្រឹងគុណភាពវិស័យឧត្តមសិក្សាឱ្យក្លាយជាមណ្ឌលមូលធនបញ្ញាជាតិ និង ឃ្លាំងពុទ្ធិសកល និងយកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន បុគ្គលិកសិក្សា និងសាស្ត្រាចារ្យ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ត្រូវបានរៀបចំឡើងមានដោយបង្ហាញនូវកម្មវិធីអាទិភាពចំនួនប្រាំ រួមមានៈ

- **កម្មវិធីអាទិភាពទី១ៈ** កំណែទម្រង់សាលារៀនដើម្បីការចូលរៀនមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌ (ការអប់រំចំណេះទូទៅ)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **កម្មវិធីអាទិភាពទី២៖** កែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍ (ការអប់រំនៅឧត្តមសិក្សា ការស្រាវជ្រាវ និងនវានុវត្តន៍)
- **កម្មវិធីអាទិភាពទី៣៖** លើកកម្ពស់ជំនាញសតវត្សទី២១ សម្រាប់យុវជន (ការអប់រំក្រៅប្រព័ន្ធ ការសិក្សាពេញមួយជីវិត និងការអភិវឌ្ឍយុវជន)
- **កម្មវិធីអាទិភាពទី៤៖** ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា
- **កម្មវិធីអាទិភាពទី៥៖** លើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (គោលនយោបាយ និងផែនការ ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស/ការអប់រំគ្រូ និងការវាយតម្លៃផ្អែកលើសមិទ្ធកម្ម)។

ដើម្បីសម្រេចបានកម្មវិធីអាទិភាពទាំង៥នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០២៤-២០២៨) ក្រសួងបានពង្រឹង និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំទៅក្នុងសកម្មភាពគោលនៃកម្មវិធីអាទិភាពនីមួយៗ។ បន្ថែមលើសពីនេះទៅទៀតក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមឱ្យមានយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ក្នុងគោលបំណងជំរុញការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគុណផលនៃការរៀនរបស់សិស្ស និងគុណផលការងាររបស់អ្នកអប់រំ ព្រមទាំងរបស់ប្រព័ន្ធអប់រំ ប្រកបដោយការចូលរួមនិងតម្លាភាពដើម្បីកសាងសង្គមពុទ្ធិជន។ លទ្ធផលស្រាវជ្រាវ និងឧត្តមានុវត្តពីប្រទេសជាច្រើនពន្យល់អំពីតួនាទី និងភាពចាំបាច់នៃបច្ចេកវិទ្យាឌីជីថលសម្រាប់ជានាឱ្យមានបរិវត្តកម្ម និង នវានុវត្តន៍ក្នុងវិស័យអប់រំ។ បទពិសោធទទួលបានពីបណ្តាប្រទេស និងសាលារៀនដែលបានអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំឌីជីថលបានពន្យល់ហេតុផលនិងភស្តុតាងជាច្រើន។ បច្ចេកវិទ្យាឌីជីថលបានផ្លាស់ប្តូរទម្រង់ និងលំនាំនៃការអប់រំ ការរៀន ការបង្រៀន និងការវាយតម្លៃ ផ្តល់អត្ថប្រយោជន៍ជាច្រើនសម្រាប់សិស្ស អ្នកអប់រំ និងសហគមន៍ទូទៅ។ បច្ចេកវិទ្យាឌីជីថលបានធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនិងគុណផលការងាររបស់អ្នកអប់រំ ពង្រឹងភាពជាដៃគូ រវាងសាលារៀននិង សហគមន៍ បង្កើនប្រសិទ្ធភាព សន្សំការចំណាយ និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

ដោយសារហេតុផលដ៏ចាំបាច់នេះ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានប្រគល់ភារកិច្ចឱ្យនាយកដ្ឋានគោលនយោបាយ ដឹកនាំនិងរៀបចំយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន។ ការរៀបចំយុទ្ធសាស្ត្រនេះ ធ្វើឡើងក្រោមគោលការណ៍ពិគ្រោះយោបល់ និងវិភាគគ្រប់ជ្រុងជ្រោយពីបទពិសោធជាតិ តំបន់ និងអន្តរជាតិ។

ក្នុងដំណាក់កាលដំបូង ក្រោមជំនួយបច្ចេកទេសពីទីប្រឹក្សារបស់នាយកដ្ឋានគោលនយោបាយ ក្រុមការងារនៃនាយកដ្ឋាន និងទីប្រឹក្សាបច្ចេកទេស បានវិភាគគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឌីជីថលសម្រាប់ការអប់រំរបស់ប្រទេសជាច្រើន គិតទាំងប្រទេសកំពុងអភិវឌ្ឍនិងអភិវឌ្ឍ ដូចជា កេនយ៉ា សិង្ហបុរី កូរ៉េខាងត្បូង អូស្ត្រាលី អេស្តូនី ឥណ្ឌា ប្រេស៊ីល ហ្វាំងឡង់ សហភាពអារ៉ាប់រួម អាហ្វ្រិកខាងត្បូង សហរដ្ឋអាមេរិក ប្រទេសជាសមាជិកនៃអង្គការ OECD និងសហភាពអឺរ៉ុបជាច្រើនទៀត។

ដោយមានការផ្តល់ប្រឹក្សាបច្ចេកទេសពីទីប្រឹក្សារបស់នាយកដ្ឋានគោលនយោបាយ និងការប្រើលទ្ធផលនៃការស្រាវជ្រាវអំពីឧត្តមានុវត្ត ក្នុងការអនុវត្តយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ក្រុមការងាររបស់នាយកដ្ឋានគោលនយោបាយ បានរៀបចំសេចក្តីព្រាងដំបូងសម្រាប់ការពិគ្រោះយោបល់នេះ។ គោលគំនិតធំនៃការពិគ្រោះយោបល់លើកដំបូង ផ្តោតការយកចិត្តទុកដាក់លើភាពចាំបាច់នៃបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ ៖

- ធានាអភិបាលកិច្ចសាលារៀន
- អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន និងអ្នកអប់រំ
- រៀន បង្រៀន វាយតម្លៃ និងស្រាវជ្រាវសម្រាប់នវានុវត្តន៍លើវិធីសាស្ត្រគរុកោសល្យ
- អភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងធនធានសិក្សាផ្សេងទៀតឱ្យសម្បូរបែប
- ធានាសមធម៌និងបរិយាបន្នក្នុងការអប់រំ ជាពិសេសសម្រាប់សិស្ស គ្រូបង្រៀន គ្រួសារជួបការលំបាក នៅជនបទ និងខ្វះឱកាសទទួលបានការអប់រំប្រកបដោយគុណភាព។

ការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ដោយមានការចូលរួមនិងមានបរិយាបន្នអាចនាំឱ្យមានការបង្កើតយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន សិស្ស អ្នកអប់រំ សហគមន៍ និងមាតាបិតា។

បន្ថែមលើការស្រាវជ្រាវពីឧត្តមានុវត្តពីប្រទេសផ្សេងៗ នាយកដ្ឋានគោលនយោបាយបានរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាច្រើន។ នាយកដ្ឋានគោលនយោបាយ បានរៀបចំកិច្ចប្រជុំលើកដំបូង នៅទីក្រុងភ្នំពេញ ក្នុងខែតុលា ឆ្នាំ២០២២។ កិច្ចប្រជុំនេះមានការចូលរួមពីនាយកដ្ឋាននានារបស់ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ រួមមាន អង្គការ UNICEF, World Education, EdTech Hub, Open Institute, EU, KOICA និង ក្រុមហ៊ុន Metfone និង ក្រុមហ៊ុន Sangapac Anuwat។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការចូលរួមរបស់តំណាងសាលារៀន ដែលត្រូវអនុវត្តគោលការណ៍ឌីជីថលសម្រាប់ការអប់រំ មានសារៈសំខាន់ដែលមិនអាចខ្វះបានក្នុងការរៀបចំយុទ្ធសាស្ត្រនេះ។ នាយកដ្ឋានគោលនយោបាយ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិមួយលើក នៅខេត្តកំពង់ចាម ក្នុងខែសីហា ឆ្នាំ២០២៣។ សិក្ខាសាលាពិគ្រោះយោបល់នេះមានការចូលរួមពីតំណាងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុកខណ្ឌ និងតំណាងសាលារៀន បឋមសិក្សា និងមធ្យមសិក្សាជាច្រើនរូប។ សិក្ខាសាលាបានឆ្លុះបញ្ចាំងពីភាពចាំបាច់ និងភាគីពាក់ព័ន្ធនៃ សេចក្តីព្រាងយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ជាមួយនឹងបរិបទសាលារៀននៅកម្ពុជា។

ដោយសារយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀនមានភាពចាំបាច់សម្រាប់ធានាឱ្យមាន បរិវត្តកម្ម និងនវានុវត្តន៍ក្នុងវិស័យអប់រំ នាយកដ្ឋានគោលនយោបាយ ក៏បានរៀបចំសិក្ខាសាលាពិគ្រោះ យោបល់ថ្នាក់ជាតិមួយលើកទៀត ដោយមានការចូលរួមពីតំណាងពីក្រសួងនានារបស់រដ្ឋាភិបាល ដៃគូ អភិវឌ្ឍ ក្រុមហ៊ុនឯកជន និងគ្រឹះស្ថានអប់រំឧត្តមសិក្សា។ តំណាងក្រសួងនៃរដ្ឋាភិបាល រួមមាន ក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ តំណាងដៃគូអភិវឌ្ឍបានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ រួមមាន ADB, UNICEF, USAID, UNESCO, KAPE, KOICA, World Education, NEP, TFC, EdTech Hub, Asia Foundation។ តំណាងក្រុមហ៊ុនឯកជនជំនាញបច្ចេកវិទ្យាសម្រាប់ការអប់រំ រួមមាន ក្រុមហ៊ុន Metfone, CAMEMIS Solutions, POSCAR Digital, Smart និង Sangapac Anuwat។ បន្ថែមពីលើសិក្ខាសាលាពិគ្រោះ យោបល់ និងកិច្ចប្រជុំនានា នាយកដ្ឋានគោលនយោបាយក៏បានទទួលយោបល់សំណេរពីសមាជិកនៃ ក្រុមការងារវិស័យអប់រំរបស់ដៃគូអភិវឌ្ឍ ដូចជាតំណាងអង្គការ UNESCO, JICA, VVOB។

ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ និងអ្នកអនុវត្តន៍នៅកម្រិតសាលារៀន យុទ្ធសាស្ត្រនេះ នឹងរួមចំណែកយ៉ាងធំធេងដល់ការធ្វើបរិវត្តកម្មនិងនវានុវត្តន៍ក្នុងការអប់រំ និងលើក កម្ពស់គុណផលការងាររបស់ប្រព័ន្ធអប់រំ ដោយបំពាក់នូវបំណិន និងផ្លាស់ប្តូរឥរិយាបថសិស្ស សម្រាប់ ការងារក្នុងយុគឧស្សាហកម្ម៤.០ និងបញ្ញាសិប្បនិម្មិត។

# យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន

## ១. ចក្ខុវិស័យ

កសាងប្រព័ន្ធគាំទ្ររឹងមាំផ្នែកបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ ដើម្បីបង្កើតបានវប្បធម៌រៀនពេញមួយជីវិតនិងសង្គមពុទ្ធិជន។

## ២. គុណតម្លៃ

យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន មានតួនាទីលើកគុណតម្លៃនៃការអប់រំ។ គ្រូបង្រៀន អ្នកអប់រំ អ្នកសិក្សា សហគមន៍ មាតាបិតា និងភាគីពាក់ព័ន្ធ យកទៅអនុវត្តដើម្បីជានាបរិវត្តកម្មអប់រំប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន ឆ្លើយតបនឹងតម្រូវការ និងការផ្លាស់ប្តូរនៃបរិបទសេដ្ឋកិច្ចសង្គម វិទ្យាសាស្ត្រ និងការអភិវឌ្ឍមូលធនមនុស្ស។ បរិវត្តកម្មអប់រំនឹងលើកតម្កើងគុណតម្លៃនៃការរៀន និងជានាបរិយាបន្ននៃការរៀន ដោយប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ។

- សង្គមពុទ្ធិជន៖ ជាសង្គមមួយពោរពេញដោយ អ្នករៀនចង់ចេះចង់ដឹង អ្នកគិតម្ចាស់ការ អ្នកស្រាយបញ្ហា ពលរដ្ឋសកល និងពលរដ្ឋឌីជីថល
- ភាពជាពលរដ្ឋឌីជីថល៖ មានបំណងលើកទឹកចិត្តឱ្យប្រើបច្ចេកវិទ្យាឌីជីថល ប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវ
- វប្បធម៌សិក្សាពេញមួយជីវិត៖ លើកកម្ពស់ការសិក្សាពេញមួយជីវិត និងលើកទឹកចិត្តអ្នកសិក្សាឱ្យបន្តការរៀន និងបង្កើតឱកាសអភិវឌ្ឍបុគ្គល និងវិជ្ជាជីវៈជាប្រចាំ
- ការត្រៀមសម្រាប់អនាគត៖ ការត្រៀមខ្លួនដោយមានជំនាញ ចំណេះដឹង និងការប្តូរឥរិយាបថសម្រាប់បំពេញកិច្ចការ ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម៤.០ និងឧស្សាហកម្មបន្ទាប់ទៀត
- ភាពងាយស្រួល៖ ទីតាំងភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គម យេនឌ័រ ពិការភាព ការរើសអើងផ្សេងៗ លែងជាឧបសគ្គនៃការរៀនរបស់អ្នកសិក្សាគ្រប់រូប
- ឆ្លើយតបនឹងតម្រូវការជាក់ស្តែង៖ ការអប់រំបំពេញតម្រូវការជាក់លាក់ ឆ្លើយតបនឹងតម្រូវការភាសា វប្បធម៌ ប្រពៃណី សេដ្ឋកិច្ច សង្គម វិទ្យាសាស្ត្រ បច្ចេកវិទ្យា
- ភាពជាដៃគូក្នុងមូលដ្ឋាន៖ ភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន ដូចជាអង្គការសហគមន៍ ឧស្សាហកម្មគ្រួសារ សហគ្រាសក្នុងមូលដ្ឋាន រួបរួមគ្នាបំពេញតម្រូវការរបស់អ្នកសិក្សា និងសាលារៀន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣. បេសកកម្ម

យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន មានបេសកកម្មធ្វើបរិវត្តកម្ម និងនវានុវត្តន៍ក្នុងវិស័យអប់រំ ដើម្បីបង្កើតសង្គមពុទ្ធិជន។ យុទ្ធសាស្ត្រនេះនឹងរួបរួមគ្រប់ភាគី ជានាឱ្យ៖

- អ្នកសិក្សាអភិវឌ្ឍគុណសម្បទាក្លាយជាពលរដ្ឋពេញលេញគឺពុទ្ធិជន
- អ្នកសិក្សាប្រកាន់អាកប្បកិរិយាទទួលខុសត្រូវចំពោះសង្គម
- អ្នកសិក្សាមានសមត្ថភាពប្រើវិជ្ជាឌីជីថលដើម្បីរួមចំណែកដល់វឌ្ឍនភាពសង្គមនិងសេដ្ឋកិច្ច
- អ្នកអប់រំក្លាយជាអ្នកដឹកនាំដែលមានចក្ខុវិស័យ និងឆន្ទៈ ក្នុងការផ្លាស់ប្តូរឥរិយាបថសិស្ស
- អ្នកអប់រំក្លាយជាអ្នកដឹកនាំពូកែលើកទឹកចិត្តសិស្សឱ្យក្លាយជាពុទ្ធិជន
- សាលារៀនមានបរិស្ថានមេត្រីភាពនិងសហការ ដើម្បីបង្កើតសង្គមពុទ្ធិជន
- កម្មវិធីសិក្សាឌីជីថលលើកកម្ពស់ការប្រតិបត្តិគុណសម្បទាសតវត្សរ៍ទី២១
- សហគមន៍ និងមាតាបិតាក្លាយជាដៃគូរបស់សាលារៀន ដើម្បីបង្កើតសង្គមពុទ្ធិជន
- ភាគីពាក់ព័ន្ធ និងដៃគូបច្ចេកទេស គាំទ្រដល់សាលារៀន ដើម្បីបង្កើតសង្គមពុទ្ធិជន។

## ៤. លទ្ធផលអប់រំ

មាតាបិតា អ្នកសិក្សា និយោជក អ្នកអប់រំ និងសង្គមទាំងមូលរំពឹងបានផលខ្ពស់ពីការអប់រំ។ ពួកគេចង់ឱ្យការអប់រំអភិវឌ្ឍសង្គមមួយពោរពេញដោយពលរដ្ឋពេញលេញ ឬសង្គមពុទ្ធិជន។ សង្គមពុទ្ធិជន គឺពោរពេញដោយមនុស្សពូកែ។ មនុស្សពូកែ គឺមានគុណសម្បទាការងារ គុណសម្បទាឌីជីថល មានសមត្ថភាពទំនាក់ទំនងសង្គម មានឥរិយាបថជាពលរដ្ឋសកលនិងពលរដ្ឋឌីជីថល ទទួលខុសត្រូវចំពោះសង្គម ប្រកាន់ចរិតស្ថាបនា លើកតម្កើងក្រមសីលធម៌ មានទម្លាប់រៀនចង់ចេះចង់ដឹង ប្រើបំណិនគិតម្ចាស់ការ និងស្រាយបញ្ហា។

ការស្រាវជ្រាវជាច្រើន និងជាបន្តបន្ទាប់បានបង្ហាញភស្តុតាងអំពីតួនាទីរបស់បច្ចេកវិទ្យាឌីជីថលក្នុងការធ្វើបរិវត្តកម្ម និងនវានុវត្តន៍ក្នុងការអប់រំ។ បច្ចេកវិទ្យាឌីជីថលមានសក្តានុពលជួយសាលារៀនឱ្យបំពេញក្តីរំពឹងរបស់សង្គម ដូចរៀបរាប់ខាងក្រោម។ ឧទាហរណ៍ ភាគីពាក់ព័ន្ធទាំងអស់អាចរួបរួមគ្នាជាមួយសាលារៀន ដើម្បីបង្កើតសង្គមពុទ្ធិជន។ សង្គមពុទ្ធិជនពោរពេញដោយពលរដ្ឋដែលជាអ្នករៀនចង់ចេះចង់ដឹង អ្នកគិតម្ចាស់ការ ពលរដ្ឋសកល ពលរដ្ឋឌីជីថល និងអ្នកស្រាយបញ្ហា។ ពុទ្ធិជនជំនាន់ថ្មីនឹងក្លាយជាអំណាចនៃការផ្លាស់ប្តូរសង្គមឆ្ពោះទៅរកនិរន្តរភាពនៃសន្តិភាពនិងចីរភាពអភិវឌ្ឍន៍។ ពុទ្ធិជននឹងរួបរួមគ្នាដើម្បីជានាសម្រេចចក្ខុវិស័យរបស់ប្រទេស ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ

២០៣០ និងប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ ក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀននេះ ពុទ្ធិជនត្រូវមានគុណសម្បទា ដូចជា ៖

### ៤.១ អ្នកសិក្សាចង់ចេះចង់ដឹង

សាលារៀនបណ្តុះវប្បធម៌ឱ្យសិស្សក្លាយជាអ្នកសិក្សាចង់ចេះចង់ដឹង និងពូកែបង្កើតសំណួរសួរសំណួរ ក្នុងសកម្មភាពរៀនក្នុងថ្នាក់និងក្រៅថ្នាក់ និងតាមបច្ចេកវិទ្យាឌីជីថល។ គុណតម្លៃនៃការចង់ចេះចង់ដឹងជាឧបករណ៍និងដំណើរការសម្រាប់អភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួននិងវិជ្ជាជីវៈ។ អ្នកសិក្សាដែលមានចរិតចង់ចេះចង់ដឹងជាចំណែកនៃសង្គមពុទ្ធិ និងមានគំនិតច្នៃប្រឌិត និងវុឌ្ឍិចរិយា ក្នុងការផ្លាស់ប្តូរប្រកបដោយវឌ្ឍនភាព។ អ្នកសិក្សាចង់ចេះចង់ដឹងប្រើចំណេះដឹង បំណិន ជំនាញ និងវុឌ្ឍិចរិយា ដើម្បីលើកកម្ពស់ផលិតភាព ប្រសិទ្ធផល កំណើន និងស្រាយបញ្ហាប្រឈមក្នុងស្ថានភាពជាក់ស្តែង។ ឆ្លើយតបនឹងក្តីរំពឹងនេះ សាលារៀនត្រូវបំពេញបេសកកម្មមួយ ដើម្បីប្រែក្លាយសិស្សឱ្យទៅជាអ្នកសិក្សាចង់ចេះចង់ដឹង និងពូកែឆ្ងល់ និងពូកែសួរសំណួរ។

ក្នុងយុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០ បច្ចេកវិទ្យាឌីជីថលផ្តល់ឱ្យសិស្សនូវលទ្ធភាពទទួលព័ត៌មាន និងធនធាននៃចំណេះដឹង និងបំណិនដ៏ច្រើនសន្ធឹកសន្ធាប់។ ឧបករណ៍ស្រាវជ្រាវតាមអ៊ីនធឺណិត គេហទំព័រអប់រំ បញ្ញាសិប្បនិម្មិត ទូរនិម្មិតបណ្ណាល័យ និងមាតិកាពហុព័ត៌មាន អាចជួយសិស្សឱ្យពង្រីកនិងបន្ថែមជម្រៅនៃការគិតនិងចំណេះដឹង អភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ និងរៀនបំណិន និងជំនាញថ្មីៗបន្ថែម។ ការចេះស្ទាត់ ក្នុងការប្រើបច្ចេកវិទ្យាឌីជីថល សិស្សអាចស្វែងយល់កាន់តែស៊ីជម្រៅ លើមុខវិជ្ជារៀននៅសាលា ស្វែងរកចំណេះដឹងថ្មីៗ បំណិនថ្មី និងរកឯកសារអប់រំជាច្រើនដែលជួយបន្ថែមអត្ថន័យឱ្យបទពិសោធសិក្សាក្នុងសាលារៀន។ គ្រូបង្រៀន និងសាលារៀន អាចប្រើបច្ចេកវិទ្យាឌីជីថល ជាថាមពលថ្មីបន្ថែម ដើម្បីដឹកនាំសិស្សឱ្យក្លាយជាអ្នកសិក្សាចង់ចេះចង់ដឹង និងពូកែ ៖

- សួរសំណួរប្រភេទផ្សេងៗ និងកម្រិតផ្សេងៗ
- បណ្តុះបទពិសោធសិក្សារីករាយ ប្រកបដោយអត្ថន័យ និងឆ្លើយតបនឹងតម្រូវការ
- ចេះសម្រេចចិត្តប្រកបដោយវិចារណញ្ញាណ
- កំណត់ជម្រើសនៃដំណោះស្រាយសម្បូរបែប និងប្រកបដោយគំនិតច្នៃប្រឌិត
- វាយតម្លៃភាពគួរឱ្យទុកចិត្ត និងសុពលភាពនៃទិន្នន័យពីប្រភពផ្សេងៗ
- ពិចារណាអំពីភស្តុតាងពីជ្រុងនៃទិដ្ឋភាពផ្សេងៗដើម្បីយល់សេចក្តីពិត
- បង្កើតជម្រើសសម្បូរបែបនៃយុទ្ធសាស្ត្រដែលអាចសម្រេចគោលបំណង
- វាយតម្លៃការអនុវត្ត លទ្ធផល ផលិតភាព ប្រសិទ្ធផល វឌ្ឍនភាព និងកំណើន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- បង្កើតចំណេះដឹងថ្មីៗដើម្បីការផ្លាស់ប្តូរប្រកបដោយបរិវត្តកម្ម និងជឿនលឿន
- ពង្រីកនិងភ្ជាប់ចំណេះដឹងថ្មីៗរៀនពីសាលាទៅនឹងស្ថានភាពពិតជាក់ស្តែង។

## ៤.២ អ្នកគិតម្ចាស់ការ

អ្នកគិតម្ចាស់ការជាសម្បត្តិដ៏មានតម្លៃសម្រាប់សង្គមពុទ្ធិជន។ អ្នកគិតម្ចាស់ការតែងតែនាំមកនូវគំនិតនិងទស្សនៈថ្មីៗ និងជំរុញគំនិតផ្តួចផ្តើមថ្មីៗ សម្រាប់លើកតម្កើងការច្នៃប្រឌិត និងនវានុវត្តន៍ក្នុងគ្រប់វិស័យ។ អ្នកគិតម្ចាស់ការមានបេះដូងជាអ្នកជួយ មានចិត្តជាអ្នកបង្កើតផលិតផលថ្មីនិងនវានុវត្តន៍។ អ្នកគិតម្ចាស់ការមានជំនឿថា ការជួយអ្នកដទៃជាការចាប់ផ្តើមបង្កើតគំនិតច្នៃប្រឌិតនិងនវានុវត្តន៍ ឈានទៅរកការផ្លាស់ប្តូរប្រកបដោយវុឌ្ឍិភាព និងផលិតភាពក្នុងគ្រប់វិស័យ។

ក្នុងយុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០ បច្ចេកវិទ្យាឌីជីថលផ្តល់អំណាចដល់គ្រូបង្រៀនឱ្យដឹកនាំសិស្សរៀនដើម្បីអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់និងគិតម្ចាស់ការ។ បច្ចេកវិទ្យាឌីជីថលជួយសិស្សឱ្យចាប់យកទំនាក់ទំនងមនុស្សក្នុងគ្រប់ជ្រុងនៃពិភពលោក។ សិស្សអាចពិភាក្សាគំនិតតាមអ៊ីនធឺណិត និងរៀនជាមួយបញ្ញាសិប្បនិម្មិត និងពីប្រភពអ៊ីនធឺណិត។ សិស្សអាចសហការជាមួយមនុស្សក្នុងបណ្តាញសង្គមដើម្បីការរៀនជាមួយគ្នា រៀនចំណេះដឹងនិងបំណិនថ្មីពីប្រព័ន្ធនិងបណ្តាញបច្ចេកវិទ្យា។ សាលារៀន គ្រូបង្រៀន អ្នកអប់រំ អាចប្រើបច្ចេកវិទ្យាឌីជីថលជាមធ្យោបាយដ៏មានឥទ្ធិពល ជួយសិស្សឱ្យក្លាយជាអ្នកគិតម្ចាស់ការ និងមានភាពពូកែក្នុងការ ៖

- រក្សាភាពជឿជាក់លើគុណតម្លៃ និងគុណភាពនៃគំនិត
- បណ្តុះឆន្ទៈរកជម្រើសនៃដំណោះស្រាយសម្បូរបែប
- ជំរុញចិត្តឱ្យចង់រៀន ចង់ចេះចង់ដឹង ព្យាយាមសួរសំណួរ និងបង្កើតគំនិតច្នៃប្រឌិតច្រើន
- ជំរុញការផ្លាស់ប្តូរការគិត ដើម្បីពង្រីកផលិតភាព ប្រសិទ្ធភាព និងកំណើន
- ជ្រើសរើសសេចក្តីសម្រេចចិត្តដែលមានអាទិភាព និងជានាសម្រេចលទ្ធផលខ្ពស់
- មានគណនេយ្យភាពក្នុងការតម្រង់ទិស និងកំណត់សេចក្តីសម្រេចចិត្តឱ្យជានាបាននូវលទ្ធផល
- ទទួលយកការលំបាក និងបញ្ហាជាមេរៀន និងជាឱកាសសម្រាប់ការផ្លាស់ប្តូរ
- មើលទស្សនៈផ្សេងគ្នា ក្នុងវិមាត្រថ្មី សម្រាប់ការផ្លាស់ប្តូរ។

## ៤.៣ ពលរដ្ឋសកល

ពលរដ្ឋសកលជាប្រភេទមនុស្សមានការតាំងចិត្ត ក្នុងការលើកកម្ពស់យុត្តិធម៌ និងការអភិវឌ្ឍប្រកបដោយសមធម៌និងចីរភាពនៅទូទាំងសកលលោក។ យោងតាមគោលការណ៍ណែនាំឆ្នាំ២០១៥

របស់អង្គការយូណេស្កូ ពលរដ្ឋសកលប្រើបំណិនគិតកម្រិតខ្ពស់ ដើម្បីស្រាយបញ្ហា ឱ្យតម្លៃទៅលើពហុភាពនិងនានាភាពនៃវប្បធម៌ ប្រើបំណិនសហការ ប្រកាន់ឥរិយាបថនិងចរិតស្ថាបនា និងទទួលខុសត្រូវចំពោះសង្គម។

ក្នុងយុគឌីជីថល បច្ចេកវិទ្យាឌីជីថលដើរតួនាទីសំខាន់ ជួយសិស្សឱ្យមានចំណងភ្ជាប់ជាមួយសហគមន៍សកលលោកនិងស្វែងយល់ស៊ីជម្រៅអំពីអន្តរវប្បធម៌ នានាភាព និងពហុភាពនៃវប្បធម៌។ បច្ចេកវិទ្យាឌីជីថលមានឥទ្ធិពលជួយសិស្សឱ្យរៀនតាមទម្រង់និងលំនាំផ្សេងៗគ្នាជាច្រើនប្រភេទ។ សិស្សអាចប្រើបច្ចេកវិទ្យាឌីជីថល ដូចជា វីដេអូ សហការតាមអ៊ីនធឺណិត វេទិកាបណ្ដាញសង្គម ChatGPT បញ្ញាសិប្បនិម្មិតបង្កើតរូបភាពនិងវីដេអូ និងបញ្ញាសិប្បនិម្មិតសរសេរអត្ថបទ។ សិស្សមានឱកាសបង្កើតអន្តរទំនាក់ទំនងជាមួយមិត្តភក្ដិមកពីប្រទេស និងវប្បធម៌ផ្សេង និងចែករំលែកបទពិសោធជាមួយពិភពលោកយ៉ាងទូលំទូលាយ។

បច្ចេកវិទ្យាឌីជីថលជួយសិស្សឱ្យចេះប្រើព័ត៌មានពីប្រភពអ៊ីនធឺណិត សិក្សាចំណេះដឹងថ្មី បំណិនថ្មីពីវេទិការៀនតាមអ៊ីនធឺណិត និងលើកទឹកចិត្តសិស្សឱ្យក្លាហានចូលរួមដោះស្រាយបញ្ហាសកល។ ការតភ្ជាប់ឧបករណ៍ និងធនធានឌីជីថល ជួយសម្រួលដល់ការអភិវឌ្ឍបំណិនទំនាក់ទំនងមនុស្ស និងយល់អន្តរវប្បធម៌ យល់ចិត្តមនុស្សក្នុងបរិបទវប្បធម៌ខុសគ្នា និងបណ្ដុះភាពជាពលរដ្ឋសកលក្នុងចំណោមសិស្ស។ សាលារៀនប្រើបច្ចេកវិទ្យាឌីជីថលមានឥទ្ធិពលកាន់តែសម្បូរបែប ជួយដល់ការផ្លាស់ប្ដូរឥរិយាបថ ទម្លាប់ ការគិតរបស់សិស្ស និងប្រែក្លាយសិស្សឱ្យទៅជាពលរដ្ឋសកល និងមានភាពពូកែក្នុងការ ៖

- ស្វែងយល់ពីកិច្ចសហការឆ្លងដែន ដើម្បីស្រាយបញ្ហាប្រឈមរួមគ្នា
- យល់ស៊ីជម្រៅអំពីទំនាក់ទំនង ទស្សនៈ និងគុណតម្លៃសកល
- ទទួលយកភាពចម្រុះ នានាភាព និងពហុភាពនៃវប្បធម៌ ទស្សនៈ និងគំនិត
- ស្នើជម្រើសនៃដំណោះស្រាយនៃបញ្ហា កម្រិតមូលដ្ឋាន តំបន់ និងពិភពលោក
- ប្រើបញ្ហាប្រឈមនិងការលំបាកជាមេរៀន និងឱកាសសម្រាប់ការផ្លាស់ប្ដូរ
- ភ្ជាប់ការយល់ដឹងផ្ទាល់ខ្លួនអំពីបរិបទក្នុងស្រុកជាមួយព្រឹត្តិការណ៍សកល
- រួមជាមួយសហគមន៍ក្នុងស្រុក ជាតិ និងពិភពលោក ដើម្បីស្រាយបញ្ហាសកល
- លើកតម្កើងគុណតម្លៃនិងគុណសម្បត្តិផ្ទាល់ខ្លួនឱ្យមានឥទ្ធិពលជួយដល់មនុស្ស
- ធ្វើជាគំរូមនុស្ស គិតល្អ ប្រើពាក្យល្អ និងការប្រព្រឹត្តល្អ
- លើកកម្ពស់យុត្តិធម៌ សមធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាព។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៤.៤ ពលរដ្ឋឌីជីថល

ភាពជាពលរដ្ឋឌីជីថលជាដំណើរការជានាភាពរីកចម្រើនផ្ទាល់ខ្លួន និងអភិវឌ្ឍវិជ្ជាជីវៈ ដោយប្រើបច្ចេកវិទ្យាឌីជីថលជាមធ្យោបាយចម្បង។ ភាពជាពលរដ្ឋឌីជីថល គឺសំខាន់សម្រាប់ក្មេងក្នុងយុគឌីជីថល។ វិជ្ជាឌីជីថលជួយក្មេងជំនាន់ក្រោយឱ្យអភិវឌ្ឍបំណិន ចំណេះដឹង និងផ្លាស់ប្តូរឥរិយាបថ ក្នុងបរិបទសេដ្ឋកិច្ច និងសង្គមឌីជីថល។ ពលរដ្ឋឌីជីថល គឺរស់ រៀន និងធ្វើការក្នុងពិភពឌីជីថល ប្រកបដោយក្រមសីលធម៌ សុវត្ថិភាព និងសន្តិសុខ។ ពលរដ្ឋឌីជីថលមានឥទ្ធិពលផ្លាស់ប្តូរសង្គមជាវិជ្ជមាន ព្រោះពួកគេមានសមត្ថភាពជំរុញឱ្យមានគំនិតច្នៃប្រឌិតសម្បូរបែបដោយប្រើវិជ្ជាឌីជីថល។ ពលរដ្ឋឌីជីថលត្រូវការគុណតម្លៃ ឥរិយាបថ សមត្ថភាពប្រើវិជ្ជាឌីជីថលដើម្បីជួយសង្គម និងការអភិវឌ្ឍគ្រប់វិស័យ។ សាលារៀន អ្នកអប់រំ គ្រូបង្រៀន អាចបណ្តុះបណ្តាលសិស្សឱ្យក្លាយជាពលរដ្ឋឌីជីថល និងមានសមត្ថភាពពូកែៈ

- យល់អំពីសិទ្ធិនិងការទទួលខុសត្រូវក្នុងពិភពឌីជីថល
- យល់អំពីហានិភ័យនិងបញ្ហាប្រឈមនៃការប្រើបច្ចេកវិទ្យាឌីជីថល
- បង្ហាញការគោរពសិទ្ធិ ឯកជនភាព និងអារម្មណ៍របស់អ្នកដទៃលើបណ្តាញសង្គម
- ប្រើអាកប្បកិរិយាទទួលខុសត្រូវ ក្នុងការប្រាស្រ័យមនុស្សក្នុងបណ្តាញសង្គម
- ចេះអត់ឱន ទទួលយកនានាភាព ពហុភាព និងចម្រុះភាពនៃគំនិត និងជំនឿ
- ចេះយោគយល់ និងការអាណិតអាសូរចំពោះអ្នកដទៃក្នុងបណ្តាញសង្គម
- វាយតម្លៃភាពជឿជាក់និងទំនុកចិត្តនៃព័ត៌មានតាមប្រព័ន្ធអនឡាញ
- អនុវត្តគោលការណ៍សម្របខ្លួន ទន់ភ្លន់ និងបត់បែន ក្នុងពិភពឌីជីថល
- អនុវត្តគោលការណ៍បើកចិត្តទូលាយនិងចង់ចេះចង់ដឹងអំពីពិភពឌីជីថល។

## ៤.៥ អ្នកស្រាយបញ្ហា

អ្នកស្រាយបញ្ហាជាប្រភេទមនុស្សពូកែប្រើភស្តុតាងវិទ្យាសាស្ត្រ មានគំនិតច្នៃប្រឌិត និងមានបេសកកម្មផ្លាស់ប្តូរ ឈានទៅភាពជឿនលឿន។ ក្នុងន័យនេះ អ្នកស្រាយបញ្ហាប្រកាន់ចរិតទទួលខុសត្រូវ មានក្រមសីលធម៌ បើកចិត្តទូលាយទទួលស្គាល់បញ្ហា ទទួលយកឱកាសសម្រាប់សហការ រៀនជាប្រចាំពីកំហុស និងប្រើវិជ្ជាប្រាស្រ័យមនុស្សប្រកបដោយទំនុកចិត្ត។ លើសពីនេះទៀត អ្នកស្រាយបញ្ហាដែលមានប្រសិទ្ធភាព និងមានឥទ្ធិពល ជាបុគ្គលមានឆន្ទៈ សេចក្តីព្យាយាម និងសមត្ថភាពគ្រប់គ្រងអារម្មណ៍ក្នុងគ្រប់ស្ថានភាពលំបាក និងបញ្ហា។

ដើម្បីការផ្លាស់ប្តូរសង្គមប្រកបដោយវិជ្ជមាន សាលារៀនត្រូវបណ្តុះសិស្សឱ្យក្លាយជាអ្នកស្រាយបញ្ហា។ អ្នកស្រាយបញ្ហាអាចចាត់ទុកជាធនធានដ៏កម្រនៃសង្គម។ អ្នកស្រាយបញ្ហាជាបុគ្គលទទួលយកការប្រែប្រួលលឿននិងឥតឈប់នៃស្ថានភាពពិភពលោក និងភាពរីកចម្រើនហួសពីការគិតនៃបច្ចេកវិទ្យាឌីជីថល និងវិទ្យាសាស្ត្រ ដែលជាឧបករណ៍សម្រាប់ការដោះស្រាយបញ្ហា។ អ្នកស្រាយបញ្ហាតែងរៀនអំពីបំណិនច្រើនប្រភេទ វិជ្ជាសម្បូរបែប និងអភិវឌ្ឍគុណសម្បទាជាពុទ្ធិជន។ អ្នកស្រាយបញ្ហារួមចំណែកជួយសង្គម និងបង្កើតអនាគតត្រចះត្រចង់ និងរុងរឿង សម្រាប់មនុស្សជំនាន់ក្រោយ និងសម្រាប់ពិភពលោកទាំងមូល។

បច្ចុប្បន្ន បច្ចេកវិទ្យាឌីជីថលជាឧបករណ៍ និងដំណោះស្រាយ ជួយគាំទ្រសិស្ស គ្រូបង្រៀន និងអ្នកអប់រំឱ្យស្រាយបញ្ហាជាច្រើនជំពូក។ ជាពិសេស បច្ចេកវិទ្យាឌីជីថលលើកកម្ពស់គុណភាពនៃការរៀននិងបង្រៀន ជួយសិស្សឱ្យអភិវឌ្ឍបំណិនសម្បូរបែប ធានាបរិយាបន្នក្នុងការអប់រំ ពង្រីកផលិតភាព និងកំណើនក្នុងការងារ និងជីវភាពប្រចាំថ្ងៃ។ សាលារៀនក៏អាចបណ្តុះបណ្តាលសិស្សឱ្យក្លាយជាអ្នកស្រាយបញ្ហា ដោយប្រើបច្ចេកវិទ្យាឌីជីថល ដូចជា កម្មវិធីបំប្លែងនិម្មិត បន្ទប់ពិសោធន៍និម្មិត ហ្គេមអន្តរកម្ម កម្មវិធីសរសេរកូដ ឧបករណ៍មនុស្សយន្ត បញ្ញាសិប្បនិម្មិត។

សាលារៀនអាចប្រើបច្ចេកវិទ្យាឌីជីថលដើម្បីពង្រីកអានុភាពបន្ថែមទៀត ក្នុងការប្រែក្លាយសិស្សឱ្យទៅជាអ្នកស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព មានគុណតម្លៃ និងសមត្ថភាព៖

- ប្រើចំណេះដឹងលើមុខវិជ្ជាបច្ចេកទេសផ្សេងៗគ្នា
- ប្រើចំណេះដឹងផ្នែកស្ថិតិ និងការវិភាគទិន្នន័យ
- អនុវត្តបំណិនក្នុងការទំនាក់ទំនងអន្តរបុគ្គល
- ប្រើបំណិនក្នុងការវាយតម្លៃព័ត៌មានពីច្រើនប្រភព
- បង្ហាញបំណិនក្នុងការជ្រើសរើសដំណោះស្រាយសម្បូរបែបនិងច្នៃប្រឌិត
- ប្រើបំណិនទទួលយក និងហ៊ានប្រថុយនឹងហានិភ័យ
- ឱ្យតម្លៃពេលវេលាជាឱកាសក្នុងការស្រាយបញ្ហា
- កសាងទំនុកចិត្ត និងភាពធន់ដើម្បីជម្នះបញ្ហាប្រឈមនិងឧបសគ្គ។

## ៥. បរិវត្តកម្មអប់រំ

បរិវត្តកម្មអប់រំ ជាអភិក្រមថ្មីក្នុងការស្វែងរកដំណោះស្រាយបញ្ហាលំបាកនានាក្នុងវិស័យអប់រំ និងសំដៅធានាពង្រីកឱកាសរៀន និងលើកកម្ពស់គុណភាពនៃការរៀនគ្រប់កម្រិតសិក្សា។ ក្នុងន័យនេះ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការបង្កើតយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀនរួមចំណែកដល់ការសម្រេចចក្ខុវិស័យ ដូចមានចែងក្នុងផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាឌីជីថល និងគោលដៅអប់រំ ក៏ដូចជាក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាសម្រាប់ការអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេសឆ្នាំ២០១៦ នៃក្រសួងអប់រំ យុវជន និងកីឡា។ សាលារៀនត្រូវការយុទ្ធសាស្ត្រអប់រំឌីជីថលដែលឆ្លើយតបនឹងតម្រូវការនៃការរៀន ការបង្រៀន និងការវាយតម្លៃការសិក្សា ក្នុងសតវត្សរ៍ទី២១ និងស្ថានភាពជាក់ស្តែងរបស់សាលារៀន។ យុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀនផ្តោតការយកចិត្តទុកដាក់លើបរិវត្តកម្មអប់រំចំនួនបួន។ បរិវត្តកម្មនីមួយៗ មានយុទ្ធសាស្ត្រ លទ្ធផលរំពឹងទុក គំនិតផ្តួចផ្តើមសកម្មភាព សូចនាករ និងការកំណត់អំពីតម្រូវការធនធាន។ បរិវត្តកម្មនីមួយៗនឹងមានឥទ្ធិពលសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន ឬរុំវិលចរិយា និងឈានទៅជានាឱ្យមានកំណើន និងវឌ្ឍនភាព ៖

- សាលារៀនមានបរិយាកាសអំណោយផលសម្រាប់ការប្រើបច្ចេកវិទ្យាឌីជីថល
- អ្នកអប់រំមានតួនាទីជាអ្នកលើកទឹកចិត្ត ប្រើបច្ចេកវិទ្យាឌីជីថលក្នុងការបង្កើតសង្គមពុទ្ធិជន
- អ្នកដឹកនាំមានចក្ខុវិស័យ និងជាអ្នកស្រាយបញ្ហា ដោយប្រើវិជ្ជាឌីជីថល
- កម្មវិធីសិក្សា និងវិធីសាស្ត្រគរុកោសល្យឌីជីថល ជាឧបករណ៍បរិវត្តកម្មអប់រំ។

### ៥.១ បរិវត្តកម្មទី១៖សាលាមានបរិយាកាសអំណោយផលសម្រាប់ប្រើបច្ចេកវិទ្យាឌីជីថល

ការរាតត្បាតនៃមេរោគនិងជំងឺ COVID-19 ប្រាប់អំពីអានុភាពនៃបច្ចេកវិទ្យាឌីជីថល ក្នុងការជានាឱ្យមានបរិវត្តកម្មនិងនវានុវត្តន៍ក្នុងវិស័យអប់រំ។ ការប្រើបច្ចេកវិទ្យាឌីជីថលជាមធ្យោបាយ និងដំណោះស្រាយចាំបាច់ ចំពោះបញ្ហាប្រឈមនិងការលំបាកក្នុងប្រព័ន្ធអប់រំ។ បច្ចេកវិទ្យាឌីជីថលអាចលើកកម្ពស់អភិបាលកិច្ចល្អ និងតម្លាភាពក្នុងការគ្រប់គ្រង និងដឹកនាំសាលារៀន កែលម្អលទ្ធផលសិក្សារបស់សិស្ស និងជានាឱ្យមានបរិយាបន្នក្នុងការរៀន។ សាលារៀនចាំបាច់ត្រូវបង្កើតបរិយាកាសអំណោយផល សម្រាប់ការប្រើបច្ចេកវិទ្យាឌីជីថលក្នុងសាលារៀន ទាំងការគ្រប់គ្រង ដឹកនាំ ការរៀន ការបង្រៀន ការវាយតម្លៃ និងកម្មវិធីសិក្សា។

បរិយាកាសអំណោយផលសំដៅដល់ការជានាឱ្យមានហេដ្ឋារចនាសម្ព័ន្ធ កៀរគរធនធាននិងទេពកោសល្យ បង្កើតក្របខ័ណ្ឌគតិយុត្តិ កៀរគរហិរញ្ញវត្ថុ និងស្វែងរកការគាំទ្របច្ចេកទេសឌីជីថលដល់សាលារៀន។ អ្នកដឹកនាំសាលារៀននិងអ្នកអប់រំ គួររកដៃគូវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដូចជា ការតភ្ជាប់អ៊ីនធឺណិត ការផ្តល់ជាឧបករណ៍ឌីជីថលសម្រាប់សិស្សនិងគ្រូបង្រៀន និងការតភ្ជាប់អគ្គិសនី។ សាលារៀនគួរកៀរគរទេពកោសល្យមនុស្សក្នុងវិស័យបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ។ ក្របខ័ណ្ឌគតិយុត្តិ ដូចជាគោលនយោបាយ សេចក្តីណែនាំ និងបទប្បញ្ញត្តិច្បាប់ គួរកែសម្រួល ឬបង្កើតថ្មី

ដើម្បីអនុញ្ញាតឱ្យការប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់ការអប់រំមានភាពរលូន ប្រសិទ្ធភាព និងមានការចូលរួមពីភាគីពាក់ព័ន្ធ។ ការកៀរគរធនធានហិរញ្ញវត្ថុ និងការចូលរួមរបស់សហគមន៍និងភាគីពាក់ព័ន្ធក្នុងវិស័យឌីជីថលសម្រាប់ការអប់រំជាតម្រូវការចាំបាច់លើការប្រើបច្ចេកវិទ្យាឌីជីថលក្នុងសាលារៀន។ សាលារៀនគួរផ្ដោតការយកចិត្តទុកដាក់លើការបណ្ដុះបណ្ដាល ការរៀនបន្ត និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងអ្នកអប់រំ ឱ្យចេះស្ទាត់ប្រើបច្ចេកវិទ្យាឌីជីថលក្នុងការបង្រៀន ការរៀន និងការវាយតម្លៃការសិក្សារបស់សិស្ស ការគ្រប់គ្រងថ្នាក់រៀន ការអនុវត្តកម្មវិធីសិក្សា និងនវានុវត្តន៍លើវិធីសាស្ត្រគរុកោសល្យ។

បរិយាកាសអំណោយផលសម្រាប់ការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ ជាគោលការណ៍ស្នូល និងផ្ដល់តម្លៃដល់ការរៀនប្រកបដោយគុណភាពនិងបរិយាបន្ន។ បរិយាបន្នក្នុងការរៀនសំដៅផ្ដល់ឱកាសឱ្យអ្នកសិក្សាទាំងអស់ ដោយគិតទាំងជនមានពិការភាព ជនមានការលំបាកផ្នែកសេដ្ឋកិច្ច-សង្គមកិច្ច និងជនប្រឈមនឹងភាពងាយរងគ្រោះ ឱ្យមានឱកាសរៀនប្រកបដោយគុណភាព។ ការរៀនប្រកបដោយគុណភាពនិងបរិយាបន្ន នឹងជានាឱ្យអ្នកសិក្សារីកចម្រើន ក្នុងគ្រប់វិស័យជីវិត ដូចជា ទំនាក់ទំនងសង្គម សុវត្ថិភាពផ្លូវចិត្តនិងកាយ ឱកាសអភិវឌ្ឍសមត្ថភាពបុគ្គល និងសមត្ថភាពវិជ្ជាជីវៈ ព្រមទាំងមានវុឌ្ឍិចរិយា។

### ៥.១.១ យុទ្ធសាស្ត្រ៖ បង្កើតបរិយាកាសសុវត្ថិភាពនិងសន្តិសុខ (តាមអ៊ីនធឺណិត) សម្រាប់ការរៀន និងការបង្រៀន ប្រកបដោយគុណភាពនិងបរិយាបន្ន

ដើម្បីក្លាយជាពលរដ្ឋពេញលេញ ឬពុទ្ធិជន សិស្សចាប់ពីកុមារភាព ត្រូវទទួលបានការថែទាំ ការគាំពារ ការការពារ សេចក្ដីស្រឡាញ់ និងការគាំទ្រពីប្រព័ន្ធសាលារៀន ដូចជា គ្រូបង្រៀន អ្នកអប់រំ អ្នកដឹកនាំសាលារៀន មិត្តរួមសាលា និងសហគមន៍។ កុមារនឹងទទួលបានបទពិសោធរៀនក្នុងភាពរីករាយជាមួយបញ្ញត្តិនៃមេរៀន មានអត្ថន័យ និងភាពពាក់ព័ន្ធសម្រាប់ការងារ និងជីវភាពក្នុងពេលអនាគត។ ដោយបានប្រើបច្ចេកវិទ្យាឌីជីថលដ៏មានអានុភាព សាលារៀននឹងត្រូវផ្លាស់ប្ដូរ ទៅជាកន្លែងសុវត្ថិភាពនិងសន្តិសុខ។ សាលារៀននឹងជានាបាននូវការរៀន និងការបង្រៀនប្រកបដោយបរិយាបន្ននិងគុណភាព។

គ្រូបង្រៀន អ្នកអប់រំ អ្នកដឹកនាំ អាចប្រើបច្ចេកវិទ្យាឌីជីថលជាឧបករណ៍ និងដំណោះស្រាយដើម្បីបង្រៀនមេរៀនដែលទាក់ទាញ និងមានអន្តរកម្ម និងជានាឱ្យសិស្សពេញចិត្តក្នុងដំណើរការរៀនបង្រៀន និងវាយតម្លៃ។ គ្រូបង្រៀន អ្នកអប់រំ និងអ្នកដឹកនាំសាលារៀនអាចប្រើកម្មវិធីសិក្សាឌីជីថលជាវិធានការប្រកបដោយសុវត្ថិភាព ការពារកុមារពីការគំរាមកំហែង និងការយាយី ក្នុងគ្រប់រូបភាព តាមប្រព័ន្ធអ៊ីនធឺណិត។ អ្នកដឹកនាំ គ្រូបង្រៀន និងអ្នកអប់រំ អាចប្រើបច្ចេកវិទ្យាឌីជីថល ជាឧបករណ៍និង

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដំណោះស្រាយសម្រាប់ទាក់ទងជាមួយសហគមន៍ ឪពុកម្ដាយ និងចូលរួមជាមួយភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យសិស្សរៀនមានសុវត្ថិភាព និងសន្តិសុខ។

**លទ្ធផល៥.១.១.១៖ យ៉ាងតិចពីរឆ្នាំក្នុងការអនុវត្ត បរិយាកាសសាលារៀនមានសុវត្ថិភាពនិងសន្តិសុខ**

ក្នុងរយៈពេលយ៉ាងតិច២ឆ្នាំ គ្រូបង្រៀននិងអ្នកអប់រំ នឹងមានបទពិសោធធ្វើការ ក្នុងសាលារៀនដែលមានបរិយាកាសសុវត្ថិភាពនិងសន្តិសុខ គិតទាំងសន្តិសុខតាមអ៊ីនធឺណិត។ សិស្សក៏មានបទពិសោធរៀនក្នុងសាលាដែលមានបរិយាកាសសុវត្ថិភាព និងសន្តិសុខ។ ចំណែកកុមារក្នុងក្រុមគ្រួសារជួបការលំបាកផ្នែកសេដ្ឋកិច្ច សង្គមកិច្ច កុមារមានពិការភាព និងកុមារមានតម្រូវការរៀនពិសេស អាចទទួលបានឱកាសរៀនប្រកបដោយគុណភាព។ មាតាបិតាសិស្ស អាណាព្យាបាល និងតំណាងសហគមន៍ នឹងរាយការណ៍វិជ្ជមាននិងអំពីការពេញចិត្ត ចំពោះបរិយាកាសប្រកបដោយសុវត្ថិភាពនិងសន្តិសុខ ក្នុងសាលារៀន។ ដើម្បីធានាសម្រេចលទ្ធផលនេះ សាលារៀនត្រូវការការគាំទ្រទាំងគោលនយោបាយ និងសម្ភារៈ ពីក្រសួងអប់រំ យុវជន និងកីឡាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយសាលារៀននឹងត្រូវអនុវត្តគំនិតផ្ដួចផ្ដើមដូចខាងក្រោមនិងធានាបំពេញសូចនាករ ដូចខាងក្រោម ៖

| គំនិតផ្ដួចផ្ដើមទី១៖ ដំណើរការយន្តការកម្រិតសាលារៀនដើម្បីសុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) | |
|---|---|
| ១. | # ដៃគូនិងភាគីពាក់ព័ន្ធចម្រុះចូលរួមក្នុងយន្តការកម្រិតសាលារៀន ជួយលើកកម្ពស់សុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| ២. | % សិស្សនិងគ្រូបង្រៀនរាយការណ៍វិជ្ជមានអំពីវិធានការរបស់ក្រុមបច្ចេកទេសឌីជីថលប្រឆាំងនឹងការឆបោក ការចម្លងមេរោគ និងការយាយីពីគ្រប់រូបភាពតាមប្រព័ន្ធអ៊ីនធឺណិត |
| ៣. | # តំណាងសហគមន៍ប្រាប់អំពីតម្លៃនៃការអប់រំដែលមានសុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| ៤. | # សិស្សក្លាយជាភ្នាក់ងារសកម្មក្នុងការលើកកម្ពស់សុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| ៥. | # ព្រឹត្តិការណ៍ផ្សព្វផ្សាយការយល់ដឹងអំពីការប្រឆាំងនឹងការគំរាមកំហែង និងការយាយីពីគ្រប់រូបភាពតាមប្រព័ន្ធអ៊ីនធឺណិត |

| | |
|---|---|
| គំនិតផ្តួចផ្តើមទី២៖ ផ្តល់តម្លៃដល់ផែនការ និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសន្តិសុខ ក្នុងសាលារៀន (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) | |
| ១. | # ដៃគូចម្រុះភាគីចូលរួមបង្កើតផែនការ និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| ២. | # ដៃគូចម្រុះភាគីផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដល់សាលារៀន សម្រាប់ធានាសុវត្ថិភាពនិងសន្តិសុខ (សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) ក្នុងសាលារៀន |
| ៣. | $ ចំនួនថវិកាប្រចាំឆ្នាំកៀរគរបាន សម្រាប់ដោះស្រាយការខ្វះខាត ក្នុងការអនុវត្តសកម្មភាពលើកកម្ពស់សុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| ៤. | # ករណីគំរាមកំហែង រើសអើង អាកប្បកិរិយាមិនប្រកបដោយសីលធម៌ ដែលបំផ្លាញសុវត្ថិភាព និងសន្តិសុខក្នុងសាលារៀន និងតាមប្រព័ន្ធអ៊ីនធឺណិត ត្រូវបានដោះស្រាយ ដោយយន្តការកម្រិតសាលារៀន |
| គំនិតផ្តួចផ្តើមទី៣៖ អនុវត្តកម្មវិធីសុវត្ថិភាពនិងសន្តិសុខ (សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) ក្នុងសាលារៀន | |
| ១. | # ព្រឹត្តិការណ៍លើកកម្ពស់សុវត្ថិភាព និងសន្តិសុខ រៀបចំក្នុងនិងក្រៅសាលារៀន |
| ២. | % សិស្ស អ្នកអប់រំ និងតំណាងសហគមន៍រាយការណ៍វិជ្ជមានអំពីសុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់រៀន និងបរិវេណសាលារៀន |
| ៣. | % សិស្ស និងអ្នកអប់រំ រាយការណ៍ពីភាពប្រសើរឡើង ពាក់ព័ន្ធនឹងការយល់ដឹងអំពីសុវត្ថិភាព និងសន្តិសុខក្នុងសាលារៀន (គិតទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| ៤. | # ឪពុកម្តាយរាយការណ៍វិជ្ជមានអំពីសុវត្ថិភាពនិងសន្តិសុខក្នុងបរិវេណសាលារៀន |
| ៥. | # តំណាងសហគមន៍ចូលរួមក្នុងព្រឹត្តិការណ៍លើកតម្កើងសុវត្ថិភាពនិងសន្តិសុខក្នុងសាលារៀន |

### ៥.១.២ យុទ្ធសាស្ត្រ ៖បង្កើតបរិស្ថានឌីជីថលសម្រាប់ការរៀននិងការបង្រៀន ប្រកបដោយគុណភាពនិងបរិយាបន្ន

ការស្រាវជ្រាវជាច្រើន ជាបន្តបន្ទាប់ពន្យល់អំពីភាពបត់បែន និងងាយស្រួលនៃបច្ចេកវិទ្យាឌីជីថល សម្រាប់លើកកម្ពស់គុណភាពនិងបរិយាបន្នក្នុងការរៀន និងការបង្រៀន។ បច្ចេកវិទ្យាឌីជីថល

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជួយសម្រួលដល់ការរៀនរបស់សិស្ស និងអនុញ្ញាតឱ្យសិស្សប្រើពេលវេលារៀន តាមលក្ខខណ្ឌតម្រូវរបស់ខ្លួន។ បច្ចេកវិទ្យាឌីជីថលជួយគ្រូបង្រៀនរៀបចំមេរៀន ដឹកនាំការរៀន បង្រៀន វាយតម្លៃលទ្ធផលសិក្សា និងផ្តល់មូលវិចារកែលម្អទម្លាប់ ឥរិយាបថ និងវិធីរៀនរបស់សិស្ស ដោយពុំមានលក្ខខណ្ឌកំណត់ដោយពេលវេលា និងទីកន្លែង។

បច្ចេកវិទ្យាឌីជីថលបង្កលក្ខណៈងាយស្រួលក្នុងការរក្សាមេរៀន និងការបង្កើតមេរៀនសម្រាប់សិស្សនិងគ្រូបង្រៀន ប្រើតាមលក្ខខណ្ឌតម្រូវរបស់ខ្លួន។ បច្ចេកវិទ្យាឌីជីថលជួយសិស្សឱ្យទទួលបានបទពិសោធអន្តរកម្ម ជាមួយមេរៀនតាមប្រព័ន្ធឌីជីថល រៀនស៊ីជម្រៅ ស្របតាមសមត្ថភាព និងលទ្ធភាពផ្ទាល់ខ្លួន។ ឧទាហរណ៍ ធនធានសិក្សាឌីជីថល ដូចជា វីដេអូពិសោធន៍និម្មិត ពិសោធន៍ទូរនិម្មិត និងការលេងហ្គេមដើម្បីការរៀនធ្វើឱ្យការរៀនកាន់តែមានថាមពលនិងទាក់ទាញសម្រាប់សិស្ស។ បច្ចេកវិទ្យាឌីជីថលជាថាមពលសម្រាប់ប្តូរពីវិធីបង្រៀនបែបប្រពៃណី ដោយឱ្យសិស្សចងចាំត្រឹមអង្គហេតុ នីតិវិធី និងដំណើរការ ឱ្យទៅជាការយល់គោលគំនិត និងបញ្ញត្តិនៃមេរៀន។ សិស្សអាចចូលរួមយ៉ាងសកម្មដោយរៀនជាមួយខ្លឹមសារមេរៀនតាមប្រព័ន្ធឌីជីថល ដូចជា ឆ្លើយសំណួរ ធ្វើលំហាត់ និងរៀនតាមវេទិកាសហការក្នុងប្រព័ន្ធឌីជីថល។ បច្ចេកវិទ្យាឌីជីថលលើកកម្ពស់បរិយាបន្នក្នុងការរៀន និងការដោះស្រាយបញ្ហាដែលកើតឡើង ដោយសារទីតាំងភូមិសាស្ត្រ ពិការភាព កត្តាសេដ្ឋកិច្ច សង្គមកិច្ច ពេលវេលា។ បច្ចេកវិទ្យាឌីជីថលបង្កើតវប្បធម៌នៃការគោរព ទទួលយក និងការយល់ដឹងពីភាពខុសគ្នាភាពចម្រុះ នានាភាព និងពហុភាព ក្នុងសាលារៀន និងក្នុងសង្គម។

**លទ្ធផល ៥.១.២.១៖ ត្រឹមឆ្នាំ ២០២៨ បរិស្ថានបច្ចេកវិទ្យាឌីជីថលធ្វើឱ្យប្រសើរនូវបរិយាបន្នក្នុងការរៀនសូត្រ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស**

នៅត្រឹមឆ្នាំ២០២៨ សាលារៀននឹងប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់ធានាឱ្យសិស្សទទួលបានបទពិសោធសិក្សាប្រកបដោយគុណភាពនិងបរិយាបន្ន។ បច្ចេកវិទ្យាឌីជីថល ផ្តល់អំណាចដល់គ្រូបង្រៀនឱ្យបណ្តុះបណ្តាលសិស្សក្លាយជាពុទ្ធិជន។ ការកៀរគរភាគីពាក់ព័ន្ធ ដូចជាដៃគូអភិវឌ្ឍនិងសហគមន៍ ឱ្យចូលរួមនិងគាំទ្រជាគន្លឹះធានាលើកកម្ពស់បរិយាកាសរៀនដោយប្រើបច្ចេកវិទ្យាឌីជីថល។ ក្នុងករណីសាលារៀនក្នុងសហគមន៍មូលដ្ឋានខ្សត់ខ្សោយនិងជួបការលំបាក ក្រសួងអប់រំ យុវជន និងកីឡាថ្នាក់ជាតិ ត្រូវផ្តល់ការគាំទ្រហិរញ្ញវត្ថុនិងបច្ចេកទេស និងលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលផ្តល់ជំនួយដល់សាលារៀនផ្ទាល់។ ដើម្បីធានាឱ្យភាគីពាក់ព័ន្ធទទួលយក និងទទួលស្គាល់ភាពជោគជ័យក្នុងការប្រើបច្ចេកវិទ្យាឌីជីថល សាលារៀនត្រូវអនុវត្តគំនិតផ្តួចផ្តើម ៖

| | |
|---|---|
| គំនិតផ្ដួចផ្ដើមទី១៖ ផ្ដល់តម្លៃដល់ផែនការ និងគោលការណ៍ណែនាំអំពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការងារអភិបាលកិច្ចសាលារៀន | |
| ១. | # តំណាងសហគមន៍ ដៃគូបច្ចេកទេសឌីជីថល អ្នកអប់រំ និងអ្នកសិក្សា ចូលរួមរៀបចំផែនការ និងគោលការណ៍ណែនាំស្ដីពីការប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការអប់រំកម្រិតសាលារៀន |
| ២. | # ដៃគូជំនាញបច្ចេកវិទ្យាឌីជីថលសម្រាប់អប់រំ (EdTech) គាំទ្រនិងសហការជាមួយសាលារៀន |
| គំនិតផ្ដួចផ្ដើមទី២៖ ពង្រឹងទំនុកចិត្តលើក្រុមការងារបច្ចេកទេសឌីជីថលកម្រិតសាលារៀន ដើម្បីជួយដល់ការប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការបង្រៀន រៀន កម្មវិធីសិក្សា ការវាយតម្លៃ ការគ្រប់គ្រង | |
| ១. | % បុគ្គលិករដ្ឋបាល រាយការណ៍អំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឌីជីថល |
| ២. | # ក្រុមហ៊ុនឯកជន គ្រឹះស្ថានអប់រំ និងអង្គការសហគមន៍ គាំទ្រសាលារៀន ក្នុងការលើកកម្ពស់បរិយាកាសសិក្សាដោយប្រើធនធានឌីជីថល |
| ៣. | % អ្នកអប់រំរាយការណ៍វិជ្ជមាននិងការពេញចិត្តអំពីការទទួលបានជំនួយបច្ចេកទេស អំពីការប្រើគ្រប់គ្រងសាលារៀន ប្រព័ន្ធគ្រប់គ្រងការរៀន ផ្ដល់ដោយក្រុមការងារបច្ចេកវិទ្យាឌីជីថល |
| ៤. | % អ្នកអប់រំនិងអ្នកសិក្សារាយការណ៍វិជ្ជមាននិងការពេញចិត្តអំពីការប្រើប្រព័ន្ធគ្រប់គ្រងការរៀនក្នុងដំណើរការរៀន បង្រៀន ការវាយតម្លៃការសិក្សា និងការផ្ដល់មូលវិចារ |
| ៥. | # បញ្ជីធនធានសិក្សាតាមឌីជីថលសម្រាប់អ្នកអប់រំ និងសិស្ស ក្នុងទម្រង់ឥតគិតថ្លៃ |
| ៦. | # កម្មវិធីបណ្ដុះបណ្ដាល ស្ដីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងធនធានសិក្សាឌីជីថល សម្រាប់គោលបំណងអប់រំ ការរៀន ការបង្រៀន និងការវាយតម្លៃការសិក្សា ចាត់ចែងដោយក្រុមការងារបច្ចេកវិទ្យាឌីជីថល |

### ៥.១.៣ យុទ្ធសាស្ត្រ៖ ធានាឱ្យមានភាពជាដៃគូសម្បូរបែបដើម្បីធានាសមធម៌ឌីជីថល

ភាពជាដៃគូសម្បូរបែបមានឥទ្ធិពលសម្រាប់ផ្លាស់ប្ដូរស្ថានភាព និងលើកកម្ពស់គុណភាព និងបរិយាបន្នក្នុងការរៀនយ៉ាងខ្លាំង។ ភាពជាដៃគូសម្បូរបែប សំដៅធានាឱ្យមានសមធម៌ឌីជីថល។ សមធម៌ឌីជីថល សំដៅដល់ការលុបគម្លាតនៃការបែងចែកវណ្ណៈ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

លើកកម្ពស់ការរៀន និងការបង្រៀន ប្រកបដោយគុណភាព និងបរិយាបន្ន។ ភាពជាដៃគូសម្បូរបែបនេះ មានលទ្ធភាពជួយសហគមន៍ក្រីក្រជួបការលំបាកឱ្យទទួលបានជំនួយធនធាន និងការគាំទ្របច្ចេកវិទ្យាឌីជីថល។ សិស្សគ្រប់ៗរូបនឹងមានឱកាសស្មើគ្នា ក្នុងការទទួលបានជោគជ័យ និងការរីកចម្រើនក្នុងជីវិតសិក្សា និងសម្រាប់អនាគតនៃការងារ និងជីវិត។

**លទ្ធផល ៥.១.៣.១៖ យ៉ាងហោចណាស់ពីរឆ្នាំនៃការអនុវត្ត ទំនាក់ទំនងរវាងសាលា ជាមួយសហគមន៍ មាតាបិតា និងភាគីពាក់ព័ន្ធបច្ចេកទេសឌីជីថលមានការទុកចិត្តគ្នាកម្រិតខ្ពស់**

កិច្ចខិតខំប្រឹងប្រែងរួមគ្នា សហការគ្នា ក្នុងការកសាងទំនាក់ទំនងដ៏គួរឱ្យទុកចិត្ត រវាងសាលារៀនជាមួយសហគមន៍ មាតាបិតា និងដៃគូបច្ចេកទេសឌីជីថល នឹងមានលទ្ធផលជាវិជ្ជមាន ជួយលើកកម្ពស់បទពិសោធសិក្សាប្រកបដោយគុណភាព និងធានាបរិយាបន្ន ក្នុងការរៀនសម្រាប់សិស្សគ្រប់រូប។ ការផ្លាស់ប្តូរជាវិជ្ជមានទាំងនេះ មានប្រយោជន៍រយៈពេលវែង សម្រាប់សាលារៀន និងសហគមន៍ទាំងមូល។

| គំនិតផ្តួចផ្តើម១៖ បង្កើតបរិយាកាសអំណោយផលឱ្យមាតាបិតាចូលរួមជាមួយសាលារៀន ដើម្បីការរៀនរបស់កុមារ ដោយប្រើបច្ចេកវិទ្យាឌីជីថល នៅផ្ទះនិងក្នុងសាលារៀន | |
|---|---|
| ១. | មានគោលការណ៍ណែនាំស្តីពីភាពជាដៃគូរវាងសាលារៀនជាមួយមាតាបិតា និងសហគមន៍ ដើម្បីលើកកម្ពស់ការរៀនរបស់កុមារ ដោយប្រើបច្ចេកវិទ្យាឌីជីថល ទាំងនៅផ្ទះនិងក្នុងសាលារៀន |
| ២. | # ឪពុកម្តាយរាយការណ៍វិជ្ជមាន អំពីបទពិសោធធ្វើដៃគូជាមួយអ្នកអប់រំ និងអ្នកដឹកនាំសាលារៀន ក្នុងការជួយកុមារឱ្យរៀនតាមបច្ចេកវិទ្យាឌីជីថលនៅផ្ទះ |
| ៣. | # ព្រឹត្តិការណ៍រៀបចំដោយសហគមន៍ និងមាតាបិតាសិស្ស ដើម្បីលើកកម្ពស់ការរៀន ដោយប្រើបច្ចេកវិទ្យាឌីជីថល នៅតាមផ្ទះ និងក្នុងសាលារៀន |
| ៤. | # ចំនួនគ្រួសារក្នុងប្រភេទក្រីក្រទទួលបានជំនួយធនធាន និងឧបករណ៍ឌីជីថលសម្រាប់កូនរៀន |
| ៥. | # ឪពុកម្តាយរាយការណ៍ពីសកម្មភាពគាំទ្រដល់សាលារៀនក្នុងការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ការរៀនរបស់សិស្ស នៅតាមផ្ទះ និងនៅសាលារៀន |

| | |
|---|---|
| គំនិតផ្តួចផ្តើមទី ២៖ បង្កបរិយាកាសអំណោយផលឱ្យដៃគូបច្ចេកទេសឌីជីថល (គិតទាំងឯកជន) ជួយគាំទ្រដល់ការប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន បង្រៀន និងការគ្រប់គ្រង ក្នុងសាលារៀន និងតាមផ្ទះ | |
| ១. | មានគោលការណ៍ណែនាំកម្រិតសាលារៀន ស្តីពីកិច្ចសហការក្នុងភាពជាដៃគូ រវាងសាលារៀន និងដៃគូបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន ការបង្រៀន និងការគ្រប់គ្រងសាលារៀន |
| ២. | # ដៃគូបច្ចេកវិទ្យាឌីជីថល សហការជាមួយសាលារៀន ប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន បង្រៀន និងការគ្រប់គ្រងសាលារៀន |
| ៣. | % គ្រូបង្រៀននិងអ្នកអប់រំវាយការណ៍វិជ្ជមានអំពីភាពជាដៃគូរបស់សាលារៀន ជាមួយភាគីបច្ចេកទេសប្រើបច្ចេកវិទ្យាឌីជីថល |
| ៤. | # កុមារជួបការលំបាកបានទទួលការរៀន ដោយប្រើបច្ចេកវិទ្យាឌីជីថល និងធនធានឌីជីថល |
| ៥. | $ ចំនួនថវិកាប្រមូលបានពីដៃគូ តាមចំនួនឆ្នាំ សម្រាប់លើកកម្ពស់ការប្រើបច្ចេកវិទ្យាឌីជីថល |
| គំនិតផ្តួចផ្តើមទី៣៖ ផ្តល់អំណាចដល់យន្តការចម្រុះភាគី នៅកម្រិតសាលារៀន ដើម្បីផ្តល់មូលនិធិសម្រាប់ជានាឱ្យមានសមធម៌ឌីជីថល | |
| ១. | # ដៃគូក្នុងយន្តការចម្រុះភាគី នៅកម្រិតសាលារៀន ចូលរួមរៀបចំផែនការគាំទ្រដល់ការប្រើបច្ចេកវិទ្យាឌីជីថលក្នុងសាលារៀន |
| ២. | $ ចំនួនថវិកាប្រចាំឆ្នាំ កៀរគរពីដៃគូចម្រុះភាគី ដើម្បីគាំទ្រការតភ្ជាប់អគ្គិសនី និងអ៊ីនធឺណិត |
| ៣. | $ ថវិកាប្រចាំឆ្នាំ កៀរគរពីដៃគូចម្រុះភាគី សម្រាប់ផ្តល់ជំនួយឧបករណ៍ឌីជីថល និងធនធានសិក្សាឌីជីថល សម្រាប់សិស្ស ជាពិសេសសិស្សជួបការលំបាក និងគ្រូបង្រៀន |
| ៤. | % គ្រូបង្រៀនមានឧបករណ៍ឌីជីថលប្រើ និងធនធានអប់រំឌីជីថលឥតគិតថ្លៃ ប្រព័ន្ធគ្រប់គ្រងការរៀនរបស់សិស្ស និងបណ្ណាល័យទូរនិម្មិត |
| ៥. | # អ្នកអប់រំ និងអ្នកសិក្សាប្រើប្រព័ន្ធគ្រប់គ្រងការរៀនតាមប្រព័ន្ធឌីជីថល (LMS) |
| ៦. | % អ្នកអប់រំ និងអ្នកសិក្សាវាយការណ៍វិជ្ជមានអំពីស្ថានភាពនៃអគ្គិសនី និងអ៊ីនធឺណិត |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៥.២ បរិវត្តកម្មទី២៖ គ្រូបង្រៀន និងអ្នកអប់រំប្រកាន់តួនាទីជាអ្នកលើកទឹកចិត្ត និងជាអ្នកដឹកនាំ ដើម្បីបង្កើតសង្គមពុទ្ធិជន ដោយប្រើបច្ចេកវិទ្យាឌីជីថល

ដើម្បីបណ្តុះបណ្តាល និងផ្លាស់ប្តូរឥរិយាបថសិស្សឱ្យក្លាយជាពុទ្ធិជនសម្រាប់សង្គមពុទ្ធិ អ្នកអប់រំ និងគ្រូបង្រៀនត្រូវតែទទួលយកតួនាទីជាអ្នកជំរុញលើកទឹកចិត្ត និងជាអ្នកដឹកនាំ ក្នុងការបង្កើតវប្បធម៌នៃការរៀនពេញមួយជីវិត ការរៀនចង់ចេះចង់ដឹង ការគិតម្ចាស់ការ ភាពជាពលរដ្ឋសកល មានចំណេះវិជ្ជាឌីជីថល និងបំណិនស្រាយបញ្ហា។ ការខិតខំប្រឹងប្រែងរបស់គ្រូបង្រៀន និងអ្នកអប់រំជាកត្តាសំខាន់ក្នុងការរៀបចំសិស្សឱ្យទទួលបានភាពជោគជ័យក្នុងពិភពលោកដែលប្រែប្រួលឥតឈប់ និងត្រូវការពលរដ្ឋជាពុទ្ធិជន។ អ្នកអប់រំនិងគ្រូបង្រៀនត្រូវប្រកាន់តួនាទីយ៉ាងសំខាន់ ក្នុងការបំផុសគំនិតសិស្សតាមរយៈបទពិសោធសិក្សាផ្ទាល់ខ្លួន វិធីសាស្ត្រសិក្សាតាមវិធីសហការ និងការសិក្សាតាមប្រព័ន្ធឌីជីថល។ វិធីសាស្ត្រទាំងនេះផ្តល់សិទ្ធិអំណាចដល់សិស្សឱ្យពង្រីកបំណិនចម្រុះ ប្តូរឥរិយាបថ និងបណ្តុះអាកប្បកិរិយា ស្ថាបនា ក្រមសីលធម៌ និងគុណធម៌។ ដោយបានបំពាក់បំណិនទាំងនេះ សិស្សនឹងមានលទ្ធភាព និងសមត្ថភាពជួយដល់ការរីកចម្រើននៃសង្គមនិងសេដ្ឋកិច្ចក្នុងយុគឌីជីថល។

### ៥.២.១ យុទ្ធសាស្ត្រ៖ អភិវឌ្ឍសមត្ថភាព ទំនុកចិត្ត និងស្វ័យប្រសិទ្ធភាពរបស់អ្នកអប់រំឱ្យប្រើបច្ចេកវិទ្យាឌីជីថល

មោទនភាពរបស់គ្រូបង្រៀនជាវិស្វករ និងស្ថាបត្យករព្រលឹង។ គ្រូបង្រៀនដឹកនាំសិស្សឱ្យបង្កើតសង្គមពោរពេញដោយពុទ្ធិជន ជាមនុស្សប្រតិបត្តិវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន វុឌ្ឍិចរិយា ចិត្តមេត្តាមេត្រីភាព សង្គ្រោះ និងក្តីស្រលាញ់។ ដើម្បីឆ្លើយតបនឹងមោទនភាពនេះ គ្រូបង្រៀនត្រូវប្រកាន់តួនាទីជាអ្នកលើកទឹកចិត្ត និងអ្នកដឹកនាំពូកែអន្ទងចិត្ត។ ដូច្នេះ គ្រូបង្រៀនត្រូវប្រកាន់ឥរិយាបថជាគំរូក្នុងការអភិវឌ្ឍវិជ្ជាជីវៈអ្នកអប់រំនិងអ្នកដឹកនាំ ក្នុងបរិបទសតវត្សរ៍ទី២១។

ការវិនិយោគលើការរៀនបន្ត និងអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងភាពជាអ្នកដឹកនាំសម្រាប់អ្នកអប់រំមានសារៈសំខាន់ក្នុងការសម្រេចលទ្ធផលនៃការចង់បានរបស់ប្រព័ន្ធអប់រំ ដូចកំណត់ក្នុងយុទ្ធសាស្ត្រនេះ គោលនយោបាយផ្សេងៗទៀត និងក្របខ័ណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។ អ្នកអប់រំ រួមមានគ្រូបង្រៀន បុគ្គលិកសាលារៀន និងអ្នកដឹកនាំសាលារៀន។ ការសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈអ្នកអប់រំ និងភាពជាអ្នកដឹកនាំ សំដៅជានាបង្កើនទំនុកចិត្ត សមត្ថភាព និងស្វ័យប្រសិទ្ធភាពរបស់អ្នកអប់រំ។ ដូច្នេះអ្នកអប់រំមានមូលធនចម្បងសម្រាប់ក្នុងការ លើកទឹកចិត្ត ដឹកនាំ និងបង្រៀនសិស្សឱ្យក្លាយជាពុទ្ធិជន សម្រាប់សង្គម និងសេដ្ឋកិច្ចនៃយុគឧស្សាហកម្ម៤.០។

ដោយសារមានឱកាសរៀន និងអភិវឌ្ឍន៍វិជ្ជាជីវៈអ្នកអប់រំកាន់តែច្រើន អ្នកអប់រំនឹងបំពេញបេសកកម្មនិងកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ទាក់ទាញ និងមានគណនេយ្យភាព។ ដើម្បីឱ្យអ្នកអប់រំប្រើសមត្ថភាព ទំនុកចិត្ត និងស្វ័យប្រសិទ្ធភាពអស់សក្តានុពល ប្រព័ន្ធសាលារៀនត្រូវអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន ៖

**លទ្ធផល ៥.២.១.១៖ យ៉ាងតិចពីរឆ្នាំនៃការអនុវត្ត សមត្ថភាពឌីជីថលរបស់គ្រូបង្រៀន ជួយបង្កើនកម្រិតលទ្ធផលសិក្សារបស់សិស្ស និងគុណផលរបស់សាលារៀន**

ក្នុងរយៈពេលពីរឆ្នាំនៃការអនុវត្ត កម្រិតលទ្ធផលសិក្សារបស់សិស្ស និងគុណផលសាលារៀនមានការកើនឡើង។ ការកើនឡើងនេះកើតឡើងដោយសារ គ្រូបង្រៀននិងអ្នកអប់រំចេះស្ទាត់ប្រើបច្ចេកវិទ្យាឌីជីថល បំពេញកិច្ច និងបេសកកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។ ការវាយតម្លៃជាក់ស្តែងលើលទ្ធផលសិក្សារបស់សិស្ស និងគុណផលរបស់សាលារៀនរកឃើញថា បច្ចេកវិទ្យាឌីជីថលជួយលើកតម្កើងលទ្ធផលសិក្សារបស់សិស្ស និងគុណផលរបស់សាលារៀន។

| គំនិតផ្តួចផ្តើម១៖ បណ្តុះវប្បធម៌សហការបច្ចេកទេសជួយសហការី និងចែករំលែកចំណេះដឹងក្នុងសាលារៀន | |
|---|---|
| ១. | # អ្នកអប់រំចូលរួមគាំទ្របច្ចេកទេសជួយដល់សហការីអំពី ការប្រើបច្ចេកវិទ្យាឌីជីថលបំពេញភារកិច្ច |
| ២. | # មេរៀនបច្ចេកទេសអំពីបច្ចេកវិទ្យាឌីជីថល និងបំណិនប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់ការរៀន និងបង្រៀន មានការចែករំលែកក្នុងចំណោមអ្នកអប់រំ និងគ្រូបង្រៀន |
| ៣. | # ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និងបទពិសោធអំពីការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ការរៀន និងបង្រៀន រៀបចំក្នុងសាលារៀន និងតាមសាលារៀនផ្សេង |
| ៤. | # អ្នកជំនាញឌីជីថល ចូលរួមចែករំលែកចំណេះដឹង និងបទពិសោធជាមួយអ្នកអប់រំក្នុងសាលារៀន |
| ៥. | % អ្នកអប់រំ រាយការណ៍ពីសកម្មភាពសំខាន់ៗ ធ្វើឡើងដោយសហគមន៍វិជ្ជាជីវៈគ្រូបង្រៀន |
| ៦. | # ព្រឹត្តិការណ៍រៀបចំទៀងទាត់ ដូចជាប្រជុំ សិក្ខាសាលា រៀបចំសម្រាប់អ្នកអប់រំដើម្បីចែករំលែកឧត្តមានុវត្ត អំពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| ៧. | % អ្នកអប់រំរាយការណ៍ពីសកម្មភាពទាក់ទងនឹងការជួយដឹកនាំ និងណែនាំដល់គ្រូបង្រៀនថ្មីៗ |
| គំនិតផ្តួចផ្តើមទី២៖ ពង្រឹងការអនុវត្តផែនការកម្រិតសាលារៀន ស្តីពីការលើកកម្ពស់វប្បធម៌រៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ | |
| ១. | % អ្នកអប់រំគាំទ្រនិងអនុវត្តផែនការកម្រិតសាលារៀន ស្តីពីការលើកកម្ពស់វប្បធម៌រៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ |
| ២. | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីសកម្មភាព និងកម្មវិធីរៀនបន្ត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| ៣. | $ ចំនួនថវិកាគាំទ្រកម្មវិធីរៀននិងអភិវឌ្ឍវិជ្ជាជីវៈ កើនឡើងតាមឆ្នាំ |
| ៤. | # អ្នកអប់រំមានផែនការរៀន និងអភិវឌ្ឍវិជ្ជាជីវៈបន្ត |
| ៥. | # អ្នកអប់រំចូលរួមរៀននិងអភិវឌ្ឍវិជ្ជាជីវៈអ្នកអប់រំ តាមទម្រង់និងប្រព័ន្ធផ្សេងៗ ដូចជារៀនក្នុងកម្មវិធីមានថ្នាក់រៀនផ្ទាល់ និងកម្មវិធីតាមប្រព័ន្ធឌីជីថល |
| គំនិតផ្តួចផ្តើមទី៣ ៖ អនុវត្តកញ្ចប់ឯកសារបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលសម្រាប់អ្នកអប់រំ | |
| ១. | # កញ្ចប់ឯកសារបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថល ប្រើក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ |
| ២. | % អ្នកអប់រំ ចេះប្រើឧបករណ៍ឌីជីថល តាមការបង្រៀនក្នុងកញ្ចប់បណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលសម្រាប់អ្នកអប់រំ |
| ៣. | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីការប្រើចំណេះដឹងរៀនពីកញ្ចប់ធនធានបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលសម្រាប់អ្នកអប់រំ |
| គំនិតផ្តួចផ្តើមទី៤៖ ជំរុញការប្រើគរុកោសល្យឌីជីថល ក្នុងការបង្រៀន និងរៀនក្នុងថ្នាក់ | |
| ១. | # គ្រូបង្រៀនប្រើបច្ចេកវិទ្យាឌីជីថល និងមេរៀនឌីជីថលក្នុងថ្នាក់រៀន |
| ២. | # គ្រូបង្រៀនរៀបចំវិធីសាស្ត្របង្រៀន ការបង្រៀន និងការវាយតម្លៃ ដោយប្រើវិធីគរុកោសល្យឌីជីថល មេរៀនឌីជីថល និងវិធីរៀនតាមលក្ខណៈបុគ្គល |
| ៣. | % អ្នកអប់រំរាយការណ៍វិជ្ជមាន អំពីការលើកទឹកចិត្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងផ្តល់ស្នាដៃវិជ្ជាជីវៈឱ្យអ្នកអប់រំដែលប្រើវិធីសាស្ត្របង្រៀនបច្ចេកវិទ្យាឌីជីថល |

| | |
|---|---|
| ៤. | # អ្នកអប់រំ ចេះប្រើគេហទំព័រ និងកម្មវិធី EdTech ក្នុងការងារ និងវិជ្ជាជីវៈបង្រៀននិងការងារ |
| ៥. | % អ្នកអប់រំ ចេះប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់វាយតម្លៃការសិក្សា |
| ៦. | % អ្នកអប់រំ ចេះរចនាខ្លឹមសារមេរៀនតាមប្រព័ន្ធឌីជីថល ដោយអនុវត្តតាមគោលការណ៍សិស្សមជ្ឈមណ្ឌល គោលបំណងនៃកម្មវិធីសិក្សា និងការវាយតម្លៃគុណផលរបស់សាលារៀន |
| ៧. | % សិស្សរាយការណ៍វិជ្ជមានអំពីបទពិសោធរៀនបំណិនគិតកម្រិតខ្ពស់ក្នុងថ្នាក់ |
| ៨. | % សិស្សរាយការណ៍វិជ្ជមានអំពីបទពិសោធរៀនជាមួយគ្រូពូកែលើកទឹកចិត្ត |
| ៩. | % សិស្សរាយការណ៍វិជ្ជមានអំពីបទពិសោធរៀនតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល |

### ៥.៣ បរិវត្តកម្មទី៣៖ នាយក/នាយិកាជាអ្នកដឹកនាំមានចក្ខុវិស័យ និងជាអ្នកស្រាយបញ្ហាដោយប្រើវិជ្ជាឌីជីថល

នាយក/នាយិកាសាលារៀនត្រូវក្លាយជាអ្នកដឹកនាំដែលមានចក្ខុវិស័យ និងជាអ្នកពូកែស្រាយបញ្ហា។ អ្នកដឹកនាំមានសមត្ថភាពផ្តល់ការណែនាំ លើកទឹកចិត្ត សម្រេចចិត្ត និងសម្របខ្លួនឱ្យទាន់របត់នៃការផ្លាស់ប្តូរ និងបរិវត្តកម្មក្នុងគ្រប់វិស័យ។

អ្នកដឹកនាំសាលារៀនដែលមានចក្ខុវិស័យត្រូវប្រកាន់តួនាទីមួយយ៉ាងសំខាន់ ក្នុងការបង្កើតសង្គមពុទ្ធិជន។ សង្គមពុទ្ធិជន គឺពោរពេញដោយអ្នករៀនចង់ចេះចង់ដឹង អ្នកគិតម្ចាស់ការ ពលរដ្ឋសកល អ្នកស្រាយបញ្ហា និងពលរដ្ឋឌីជីថល។ ក្នុងយុគឌីជីថលសព្វថ្ងៃនេះ អ្នកដឹកនាំសាលារៀនដែលមានប្រសិទ្ធភាពត្រូវតែមានទាំងគុណភាព គុណតម្លៃ និងជំនាញក្នុងការដឹកនាំ ឱ្យឆ្លើយតបនឹងចក្ខុវិស័យ និងស្រាយបញ្ហាក្នុងភាពច្នៃប្រឌិត។

អ្នកដឹកនាំសាលារៀនមានចក្ខុវិស័យត្រូវទទួលខុសត្រូវ ដឹកនាំសាលានិងសហគមន៍ដោយសំអាងចក្ខុវិស័យរួមមួយ ច្បាស់លាស់ ជាមួយនឹងទិសដៅយុទ្ធសាស្ត្រប្រាកដប្រជា។ ដោយចេះស្ទាត់ប្រើបច្ចេកវិទ្យាឌីជីថល អ្នកដឹកនាំសាលារៀនមានគំនិតច្នៃប្រឌិត និងនវានុវត្តន៍ ហើយជានាកិច្ចសហការប្រកបដោយទំនុកចិត្ត។ លើសពីនេះទៀត អ្នកដឹកនាំសាលារៀនចូលរួមជាមួយភាគីពាក់ព័ន្ធក្នុងការសម្រេចចិត្តប្រកបដោយតម្លាភាព និងគណនេយ្យភាព។

អ្នកដឹកនាំសាលារៀនជាអ្នកស្រាយបញ្ហា ត្រូវមានទំនុកចិត្តក្នុងការកំណត់និងវិភាគបញ្ហា និងការលំបាក ក្នុងប្រព័ន្ធអប់រំនិងសង្គម។ ដោយចេះប្រើវិធីសាស្ត្រស្រាយបញ្ហា និងចេះស្ទាត់ក្នុងការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រើបច្ចេកវិទ្យាឌីជីថល អ្នកដឹកនាំសាលារៀនពិតជាអាចបង្កើតបរិយាកាសវិជ្ជមានសម្រាប់ការរៀននិងបង្រៀន និងធានាឱ្យមានផលិតភាពការងារខ្ពស់។ មានអ្នកដឹកនាំដែលមានចក្ខុវិស័យ និងពូកែស្រាយបញ្ហា សាលារៀននឹងដំណើរការ ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ហើយគាំទ្រដល់ភាពជោគជ័យរបស់សិស្ស និងសហគមន៍ទាំងមូល។

### ៥.៣.១ យុទ្ធសាស្ត្រ ៖ លើកកម្ពស់អភិបាលកិច្ចល្អរបស់សាលារៀន ដោយប្រើបំណិន និងវិជ្ជាផ្អែកបច្ចេកវិទ្យាឌីជីថល

ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពជាស្នូលនៃអភិបាលកិច្ចល្អរបស់សាលារៀន។ ការស្រាវជ្រាវជាច្រើន និងជាបន្តបន្ទាប់បានគូសបញ្ជាក់ថា បច្ចេកវិទ្យាឌីជីថលធានាអភិបាលកិច្ចល្អក្នុងសាលារៀន។ បច្ចេកវិទ្យាឌីជីថលផ្តល់ទិន្នន័យដ៏មានតម្លៃ ជានាភាពប្រសើរក្នុងទំនាក់ទំនងនិងសហការរវាងសាលារៀន និងដៃគូសហការ អនុញ្ញាតឱ្យមានការរៀនតាមតម្រូវការបុគ្គលរបស់សិស្ស ផ្តល់ឱកាសឱ្យសិស្សនិងគ្រូបង្រៀនប្រើធនធានសិក្សាឌីជីថលដ៏សម្បូរបែប ផ្តល់ភាពងាយស្រួលឱ្យគ្រូបង្រៀនត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងបង្កលទ្ធភាពឱ្យអ្នកដឹកនាំសាលារៀនតាមដាននិងវាយតម្លៃសមិទ្ធផលរួមរបស់សាលារៀន។

ដោយសារគ្រូបង្រៀន និងអ្នកអប់រំចេះស្ទាត់ និងប្រើបច្ចេកវិទ្យាឌីជីថលអស់សក្តានុពល ក្នុងការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សាលារៀនអាចបង្កើតបរិយាកាសវិជ្ជមានសម្រាប់ការរៀន និងការបង្រៀនឱ្យមានគុណភាព និងប្រកបដោយបរិយាបន្ន។ បរិយាកាសវិជ្ជមានជាប្រភពជួយគាំទ្រដល់ភាពជោគជ័យរបស់សិស្ស សហគមន៍ និងគ្រប់ភាគីពាក់ព័ន្ធ។

លទ្ធផលរំពឹងទុកបានពីអភិបាលកិច្ចល្អរបស់សាលារៀន គឺការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សា និងធានាឱ្យសិស្សក្លាយជាពលរដ្ឋពេញលេញ ឬជាពុទ្ធិជន។ ការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ឬលើកកម្ពស់គុណភាពនៃការរៀន និងការបង្រៀន ត្រូវពឹងអាស្រ័យលើកិច្ចការច្រើនជំពូក៖

- ការធានាឱ្យមានសមធម៌ក្នុងការអប់រំ
- ការលើកកម្ពស់គុណផលការងាររបស់អ្នកអប់រំ
- ការពង្រឹងភាពជាអ្នកដឹកនាំប្រកបដោយចក្ខុវិស័យ
- ការចូលរួមរបស់មាតាបិតា សហគមន៍ និងដៃគូបច្ចេកទេសនៃបច្ចេកវិទ្យាឌីជីថល។

ក្នុងយុគឌីជីថល អភិបាលកិច្ចល្អបានក្លាយជាទិដ្ឋភាពនៃការគ្រប់គ្រង និងដឹកនាំសាលារៀនក្នុងបរិបទឧស្សាហកម្ម៤.០។ ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ប្រព័ន្ធសាលារៀនត្រូវអនុវត្តគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីសម្រេចលទ្ធផលដូចខាងក្រោម ៖

**លទ្ធផល ៥.៣.១.១៖ យ៉ាងតិចពីរឆ្នាំក្នុងការអនុវត្ត ការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ប្រព័ន្ធគ្រប់គ្រងសាលារៀន លទ្ធផលសិក្សារបស់សិស្សនឹងមានភាពប្រសើរឡើង**

សមាហរណកម្មបច្ចេកវិទ្យាឌីជីថលក្នុងប្រព័ន្ធគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពក្នុងរយៈពេលយ៉ាងតិចពីរឆ្នាំ សាលារៀននឹងបានឃើញពីភាពប្រសើរឡើងនៃលទ្ធផលសិក្សារបស់សិស្ស។

| | |
|---|---|
| គំនិតផ្តួចផ្តើមទី១៖ អនុវត្តគោលការណ៍គណនេយ្យភាពក្នុងអភិបាលកិច្ចសាលារៀន | |
| ១. | # នៃសារផ្សព្វផ្សាយចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្ររបស់សាលារៀន គិតតាមខែ (ជួបមុខផ្ទាល់និងតាមប្រព័ន្ធឌីជីថល) |
| ២. | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសាលារៀន |
| ៣. | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីអាកប្បកិរិយារបស់អ្នកដឹកនាំសាលារៀន ក្នុងការលើកកម្ពស់ការរៀនបន្ត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ គិតទាំងវិជ្ជាឌីជីថលសម្រាប់ការអប់រំ |
| ៤. | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីអាកប្បកិរិយារបស់អ្នកដឹកនាំសាលារៀនអំពីសកម្មភាពលើកទឹកចិត្តដល់អ្នកអប់រំ និងអ្នកសិក្សា |
| ៥. | # មានឃ្លាំងទិន្នន័យឌីជីថលមួយគួរឱ្យទុកចិត្ត និងប្រើការបាន សម្រាប់ការសម្រេចចិត្ត |
| ៦. | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីតម្លាភាពនៃការប្រើធនធានសម្រាប់អភិបាលកិច្ចសាលារៀន |
| គំនិតផ្តួចផ្តើមទី២៖ អនុវត្តគោលការណ៍លើកទឹកចិត្ត ឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធ និងដៃគូបច្ចេកទេសឌីជីថល ក្នុងការសម្រេចចិត្ត និងការស្រាយបញ្ហា | |
| ១. | % អ្នកអប់រំបានអនុវត្តផែនការសាលារៀន ស្តីពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសាលារៀន |
| ២. | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីលទ្ធផលនៃការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការរៀននិងបង្រៀន |
| ៣. | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីលទ្ធផលសិក្សារបស់សិស្ស ក្រោយប្រើបច្ចេកវិទ្យាឌីជីថល |
| ៤. | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីការទទួលស្គាល់ និងឱ្យតម្លៃចំពោះវិជ្ជាជីវៈអ្នកអប់រំ និងអំពីការផ្តល់រង្វាន់លើកទឹកចិត្ត ក្នុងកម្រិតសាលារៀន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| ៥. | %អ្នកអប់រំរាយការណ៍វិជ្ជមានអំពីដំណើរការគ្រប់គ្រងសាលារៀន ដោយប្រើបច្ចេកវិទ្យាឌីជីថល |
| ៦. | # ភាគីពាក់ព័ន្ធនិងសហគមន៍រាយការណ៍វិជ្ជមានអំពីការដឹកនាំ និងអភិបាលកិច្ចរបស់សាលារៀន |

**៥.៤ បរិវត្តកម្មទី៤៖ កម្មវិធីសិក្សាឌីជីថល និងធនធានគរុកោសល្យឌីជីថល ជួយដល់បរិវត្តកម្មនិងនវានុវត្តន៍នៃការរៀននិងបង្រៀន**

កម្មវិធីសិក្សានិងវិធីសាស្ត្រគរុកោសល្យ មានអំណាចផ្លាស់ប្តូរទម្រង់នៃការអប់រំក្នុងយុគឌីជីថល ព្រោះបច្ចេកវិទ្យាឌីជីថលជំរុញភាពពាក់ព័ន្ធ លើកតម្កើងការរៀនតាមលក្ខណៈបុគ្គល ការចូលរួម ការតភ្ជាប់បណ្តាញសកល អក្ខរកម្មឌីជីថល និងបំណិនសម្រាប់អនាគត។ ការប្រើប្រាស់ឧបករណ៍ឌីជីថលក្នុងកម្មវិធីសិក្សា និងវិធីសាស្ត្រគរុកោសល្យអាចបង្កើតបទពិសោធសិក្សារបស់សិស្ស ឱ្យសកម្មស្វាហាប់ និងមានការផ្លាស់ប្តូរ។

សាលារៀននិងអ្នកសិក្សាត្រូវការកម្មវិធីសិក្សាដែលមានអត្ថន័យ និងឆ្លើយតបតម្រូវការសម្រាប់ការរៀន ការបង្រៀន ការវាយតម្លៃ និងមូលវិចារកែលម្អ។ កម្មវិធីសិក្សាជាមគ្គុទ្ទេសក៍សម្រាប់អ្នកអប់រំ ក្នុងការណែនាំ វាយតម្លៃ និងសរសេរមូលវិចារកែលម្អសិស្ស។ អ្នកសិក្សាទទួលបានការបណ្តុះបណ្តាលជំនាញ និងពង្រីកបំណិនជាច្រើនក្នុងវិស័យការងារ សង្គម ផ្លូវចិត្ត ផ្លូវអារម្មណ៍ បំណិនឌីជីថល។ អ្នកសិក្សាក៏ទទួលបានការផ្លាស់ប្តូរឥរិយាបថប្រកបដោយការទទួលខុសត្រូវ និងប្រតិបត្តិចរិតស្ថាបនា និងប្រកបដោយក្រមសីលធម៌។

- លទ្ធផលសិក្សាមានតុល្យភាព៖ កម្មវិធីសិក្សាដែលមានអត្ថន័យ និងឆ្លើយតបនឹងតម្រូវការជួយដល់ដំណើរការរៀនគួរជាទីពេញចិត្ត ប្រកបដោយអត្ថន័យ និងឆ្លើយតបតម្រូវការរបស់សិស្ស។ កម្មវិធីសិក្សាផ្តល់មាគ៌ាសិក្សាច្បាស់លាស់សម្រាប់អ្នកសិក្សា។ កម្មវិធីសិក្សាផ្តោតលើចំណេះដឹង បំណិន ឥរិយាបថ ចរិយា និងគុណតម្លៃដែលពាក់ព័ន្ធនិងមានសារៈសំខាន់។
- ការរៀនប្រកបដោយគុណភាព៖ ផ្តោតការយកចិត្តទុកដាក់លើការរៀនដោយខ្លួនឯងឬស្វ័យបុគ្គល និងការរៀនតាមលក្ខណៈបុគ្គល។ កម្មវិធីសិក្សាដែលពាក់ព័ន្ធនិងមានអត្ថន័យយកចេញមកពីប្រភពផ្សេងៗ និងក្នុងរបៀបបង្ហាញផ្សេងៗ អនុញ្ញាតឱ្យអ្នកអប់រំកែសម្រួលវិធីសាស្ត្របង្រៀន និងការវាយតម្លៃ ដើម្បីបំពេញតាមតម្រូវការ និងទម្លាប់របស់សិស្ស។ អ្នកសិក្សាមានទម្លាប់ និងសមត្ថភាពសិក្សាខុសៗគ្នា ហើយកម្មវិធីសិក្សាដែលពាក់ព័ន្ធ និងមានអត្ថន័យធានាថា អ្នកសិក្សាអាចរៀនតាមល្បឿននិងទម្លាប់ផ្ទាល់ខ្លួន។

- ជានាការចូលរួមក្នុងសកម្មភាពរៀនរបស់សិស្ស៖ កម្មវិធីសិក្សាដ៏មានអត្ថន័យ និងឆ្លើយតបនឹងតម្រូវការ លើកកម្ពស់ការចូលរួមរបស់អ្នកសិក្សា ដោយអនុវត្តគោលវិធីបង្រៀនដែលមានអន្តរកម្មច្នៃប្រឌិត និងប្រសិទ្ធភាព។ អ្នកអប់រំអាចប្រើយុទ្ធវិធីថ្មីបែបច្នៃប្រឌិត និងបច្ចេកវិទ្យាឌីជីថលដើម្បីសម្រេចគោលបំណងនៃកម្មវិធីសិក្សា និងជំរុញឱ្យអ្នកសិក្សាចូលរួមយ៉ាងសកម្ម។ អ្នកអប់រំអាចតាមដានវឌ្ឍនភាព ចំណុចខ្លាំង និងចំណុចខ្សោយរបស់សិស្ស ដោយប្រើឧបករណ៍ឌីជីថល និងវិជ្ជាឌីជីថលដើម្បីជួយអ្នកសិក្សា។
- ជានាការអភិវឌ្ឍរួមរបស់កុមារ៖ កម្មវិធីសិក្សាដែលមានអត្ថន័យ និងពាក់ព័ន្ធជួយដល់ការអភិវឌ្ឍរួមរបស់កុមារ។ ការអភិវឌ្ឍរួមរបស់កុមារសំដៅដល់ការអភិវឌ្ឍប្រព័ន្ធគិតរបស់កុមារ ការអភិវឌ្ឍអារម្មណ៍ បំណិនទំនាក់ទំនងសង្គម ការអភិវឌ្ឍសារពាង្គកាយ ភាសា និងការផ្លាស់ប្តូរការគិតឱ្យមានគំនិតច្នៃប្រឌិត។

ការតាក់តែង និងការរចនានៃកម្មវិធីសិក្សា គឺសំដៅផ្តល់លទ្ធផលអប់រំមួយ ក្នុងការបង្កើតសង្គមពុទ្ធិជន។ សង្គមពុទ្ធិជនសំដៅដល់ អ្នកសិក្សាចង់ចេះចង់ដឹង អ្នកគិតម្ចាស់ការ ពលរដ្ឋសកល ពលរដ្ឋឌីជីថល និងអ្នកដោះស្រាយបញ្ហា។ លទ្ធផលអប់រំគឺកើតចេញពីប្រសិទ្ធភាព សមត្ថភាព ទំនុកចិត្ត និងស្វ័យម្ចាស់ការ របស់អ្នកអប់រំ។ គ្រូបង្រៀន និងអ្នកអប់រំត្រូវប្រើវិធីគរុកោសល្យឌីជីថល ធនធានឌីជីថល និងវិជ្ជាឌីជីថលជាមួយសិស្ស។ ដើម្បីជានាសម្រេចលទ្ធផលសិក្សារំពឹងទុក កម្មវិធីសិក្សានិងវិធីសាស្ត្រគរុកោសល្យត្រូវតែមានភាពច្នៃប្រឌិតនិងនវានុវត្តន៍។ អ្នកអប់រំត្រូវមានគំនិតច្នៃប្រឌិត និងនវានុវត្តន៍ក្នុងការប្រើកម្មវិធីសិក្សា និងវិធីសាស្ត្រគរុកោសល្យ ជាមួយសិស្ស។

### ៥.៤.១ យុទ្ធសាស្ត្រ ៖ ផ្តល់ធនធានសិក្សាឌីជីថលសម្រាប់ការរៀន បង្រៀន និងការវាយតម្លៃ

ធនធានសិក្សាឌីជីថលផ្តល់ឱកាសឱ្យសិស្សរៀនតាមល្បឿន និងទម្លាប់បុគ្គលរបស់សិស្ស។ ធនធានសិក្សាឌីជីថលអាចរកបាន ២៤/៧ ម៉ោង នៅទីតាំងណាក៏បាន។ ធនធានសិក្សាឌីជីថលអនុញ្ញាតឱ្យសិស្សរៀនតាមតម្រូវការ ដោយពុំបារម្ភអំពីលក្ខខណ្ឌពេលវេលា និងភូមិសាស្ត្រ។ ធនធានសិក្សាឌីជីថលជួយសិស្សឱ្យរក្សាតុល្យភាពនៃការសិក្សាជាមួយនឹងការងារនិងគ្រួសារ។ អ្នកសិក្សានិងអ្នកអប់រំមានលទ្ធភាពប្រើធនធានឌីជីថល លុះណាសាលារៀនអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព។

យុទ្ធសាស្ត្រនេះសំដៅជានាឱ្យមានការប្រើអ៊ីនធឺណិតល្បឿនលឿន ការបណ្តុះបណ្តាលអ្នកអប់រំ ផ្តល់ជំនួយគាំទ្របច្ចេកទេសដល់អ្នកអប់រំឱ្យបានជាប់លាប់ និងការវាយតម្លៃការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ការរៀន បង្រៀន និងការវាយតម្លៃ។ យុទ្ធសាស្ត្រនេះជួយសាលារៀនឱ្យបង្កើនប្រសិទ្ធភាព និង

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អត្ថប្រយោជន៍នៃការប្រើបច្ចេកវិទ្យាឌីជីថល និងបង្រៀនសិស្សឱ្យត្រៀមខ្លួនទទួលជោគជ័យក្នុងយុគនៃសេដ្ឋកិច្ច និងសង្គមឌីជីថល។

**លទ្ធផល ៥.៤.១.១៖ យ៉ាងតិចពីរឆ្នាំនៃការអនុវត្ត អ្នកអប់រំមានភាពស្ទាត់ជំនាញក្នុងការប្រើកម្មវិធីសិក្សាឌីជីថលសម្រាប់ដឹកនាំការរៀន និងបង្រៀន**

ក្នុងបរិបទសេដ្ឋកិច្ច សង្គមឌីជីថល អ្នកអប់រំត្រូវមានគុណសម្បទាឌីជីថល។ គុណសម្បទាឌីជីថលសំដៅដល់បំណិន និងវិជ្ជាប្រើបច្ចេកវិទ្យាឌីជីថល និងធនធានឌីជីថល សម្រាប់ការរៀន បង្រៀន ការវាយតម្លៃលទ្ធផលសិក្សា ការផ្តល់មូលវិចារកែលម្អឥរិយាបថសិស្ស និងការប្រើកម្មវិធីសិក្សាតាមឌីជីថល។ ដើម្បីជានាសម្រេចលទ្ធផលរំពឹងទុកនេះ ប្រព័ន្ធសាលារៀន ត្រូវអនុវត្តគំនិតផ្តួចផ្តើម ខាងក្រោម ៖

| គំនិតផ្តួចផ្តើមទី១៖ ពង្រីកសមត្ថភាពអ្នកអប់រំអំពីការប្រើធនធានសិក្សាឌីជីថល | |
|---|---|
| ១. | % អ្នកអប់រំរាយការណ៍វិជ្ជមានពីការប្រើធនធានឌីជីថលសម្រាប់ការបង្រៀន ការរៀន និងវាយតម្លៃ |
| ២. | % សិស្សរាយការណ៍វិជ្ជមាននិងការពេញចិត្ត អំពីធនធានឌីជីថល មានក្នុងប្រព័ន្ធគ្រប់គ្រងការរៀនសម្រាប់ឱ្យសិស្សរៀនពីបទពិសោធរៀននិងឧបាយឬវិធីរៀនតាមលក្ខណៈបុគ្គល |
| ៣. | # អ្នកអប់រំប្រើវិធីសាស្ត្របង្រៀនតាមលក្ខណៈបុគ្គល ក្នុងថ្នាក់ និងការប្រើបច្ចេកវិទ្យាឌីជីថល |
| ៤. | % អ្នកអប់រំប្រើបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើតឯកសារវាយតម្លៃ និងវាយតម្លៃលទ្ធផលសិក្សាសិស្ស |
| ៥. | % អ្នកអប់រំទទួលការបណ្តុះបណ្តាលអំពីការរៀបចំការវាយតម្លៃ ដោយប្រើបច្ចេកវិទ្យាឌីជីថល និងផ្តល់មូលវិចារកែលម្អឥរិយាបថ និងឧបាយឬវិធីរៀនតាមលក្ខណៈបុគ្គលរបស់សិស្ស |
| ៦. | # អ្នកអប់រំប្រើប្រព័ន្ធគ្រប់គ្រងការរៀន សម្រាប់ការវាយតម្លៃការសិក្សានិងផ្តល់មូលវិចារ |
| ៧. | % សិស្សរាយការណ៍វិជ្ជមាននិងការពេញចិត្តអំពីការវាយតម្លៃ និងមូលវិចារកែលម្អឥរិយាបថរបស់សិស្ស ដែលគ្រូប្រើប្រព័ន្ធគ្រប់គ្រងការរៀនតាមបច្ចេកវិទ្យាឌីជីថល |

# ៦. តារាងសូចនាករអនុវត្ត

<table>
<tr><td colspan="2">៥.១. បរិវត្តកម្មទី១៖ សាលារៀនមានបរិយាកាសអំណោយផលសម្រាប់ការប្រើបច្ចេកវិទ្យាឌីជីថល</td></tr>
<tr><td colspan="2">យុទ្ធសាស្ត្រ ៥.១.១៖ បង្កើតបរិយាកាសសុវត្ថិភាពនិងសន្តិសុខ (សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) សម្រាប់ការរៀន និងការបង្រៀន ប្រកបដោយគុណភាពនិងបរិយាបន្ន</td></tr>
<tr><td colspan="2">លទ្ធផល៥.១.១.១៖ យ៉ាងតិចពីរឆ្នាំក្នុងការអនុវត្ត បរិយាកាសសាលារៀនមានសុវត្ថិភាពនិងសន្តិសុខ (រួមទាំងសន្តិសុខតាមអ៊ីនធឺណិត)</td></tr>
<tr><th>គំនិតផ្តួចផ្តើម និងសកម្មភាព</th><th>សូចនាករ</th></tr>
<tr><td rowspan="5">គំនិតផ្តួចផ្តើម១៖ ដំណើរការយន្តការកម្រិតសាលារៀនដើម្បីសុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត)</td><td># ដៃគូនិងភាគីពាក់ព័ន្ធចម្រុះចូលរួមក្នុងយន្តការកម្រិតសាលារៀន ជួយលើកកម្ពស់សុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត)</td></tr>
<tr><td>% សិស្សនិងគ្រូបង្រៀនរាយការណ៍វិជ្ជមានអំពីវិធានការរបស់ក្រុមបច្ចេកទេសឌីជីថល ប្រឆាំងនឹងការឆបោក ការចម្លងមេរោគ និងការយាយីគ្រប់រូបភាពតាមប្រព័ន្ធអ៊ីនធឺណិត</td></tr>
<tr><td># តំណាងសហគមន៍ប្រាប់អំពីតម្លៃនៃការអប់រំដែលមានសុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត)</td></tr>
<tr><td># សិស្សក្លាយជាភ្នាក់ងារសកម្មក្នុងការលើកកម្ពស់សុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត)</td></tr>
<tr><td># ព្រឹត្តិការណ៍ផ្សព្វផ្សាយការយល់ដឹងអំពីការប្រឆាំងនឹងការគំរាមកំហែង និងការយាយី គ្រប់រូបភាព តាមប្រព័ន្ធអ៊ីនធឺណិត</td></tr>
<tr><td>គំនិតផ្តួចផ្តើមទី២៖ ផ្តល់តម្លៃដល់ផែនការ និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និង</td><td># ដៃគូចម្រុះភាគីចូលរួមបង្កើតផែនការ និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត)</td></tr>
</table>

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| សន្តិសុខ ក្នុងសាលារៀន (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) | # ដៃគូចម្រុះភាគីផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដល់សាលារៀន សម្រាប់ធានាសុវត្ថិភាពនិងសន្តិសុខ (សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) ក្នុងសាលារៀន |
| | ចំនួនថវិកាប្រចាំឆ្នាំកៀរគរបាន សម្រាប់ដោះស្រាយការខ្វះខាត ក្នុងការអនុវត្តសកម្មភាពលើកកម្ពស់សុវត្ថិភាព និងសន្តិសុខ (រួមទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| | #ករណីគំរាមកំហែង រើសអើង អាកប្បកិរិយាមិនប្រកបដោយសីលធម៌ ដែលបំផ្លាញសុវត្ថិភាព និងសន្តិសុខក្នុងសាលារៀន និងតាមប្រព័ន្ធអ៊ីនធឺណិត ត្រូវបានដោះស្រាយ ដោយយន្តការកម្រិតសាលារៀន |
| គំនិតផ្តួចផ្តើមទី៣៖ អនុវត្តកម្មវិធីសុវត្ថិភាព និងសន្តិសុខ (សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) ក្នុងសាលារៀន | # ព្រឹត្តិការណ៍លើកកម្ពស់សុវត្ថិភាព និងសន្តិសុខ រៀបចំក្នុងនិងក្រៅសាលារៀន |
| | % សិស្ស អ្នកអប់រំ និងតំណាងសហគមន៍រាយការណ៍វិជ្ជមានអំពីសុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់រៀន និងបរិវេណសាលារៀន |
| | % សិស្ស និងអ្នកអប់រំ រាយការណ៍ពីភាពប្រសើរឡើង ពាក់ព័ន្ធនឹងការយល់ដឹងអំពីសុវត្ថិភាព និងសន្តិសុខក្នុងសាលារៀន (គិតទាំងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត) |
| | # ឪពុកម្តាយរាយការណ៍វិជ្ជមានអំពីសុវត្ថិភាពនិងសន្តិសុខក្នុងបរិវេណសាលារៀន |
| | # តំណាងសហគមន៍ចូលរួមក្នុងព្រឹត្តិការណ៍លើកតម្កើងសុវត្ថិភាពនិងសន្តិសុខក្នុងសាលារៀន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| យុទ្ធសាស្ត្រ ៥.១.២៖ បង្កើតបរិស្ថានឌីជីថលសម្រាប់ការរៀននិងការបង្រៀន ប្រកបដោយគុណភាពនិងបរិយាបន្ន | |
| លទ្ធផល ៥.១.២.១៖ ត្រឹមឆ្នាំ ២០២៨ បរិស្ថានបច្ចេកវិទ្យាឌីជីថលធ្វើឱ្យប្រសើរនូវបរិយាបន្នក្នុងការរៀន និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស | |
| គំនិតផ្តួចផ្តើមទី១៖ ផ្តល់តម្លៃដល់ផែនការ និងគោលការណ៍ណែនាំអំពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការងារអភិបាលកិច្ចសាលារៀន | # តំណាងសហគមន៍ ដៃគូបច្ចេកទេសឌីជីថល អ្នកអប់រំ និងអ្នកសិក្សា ចូលរួមរៀបចំផែនការ និងគោលការណ៍ណែនាំស្តីពីការប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការអប់រំកម្រិតសាលារៀន |
| | # ដៃគូជំនាញបច្ចេកវិទ្យាឌីជីថលសម្រាប់អប់រំ (EdTech) គាំទ្រនិងសហការជាមួយសាលារៀន |
| គំនិតផ្តួចផ្តើមទី២៖ ពង្រឹងទំនុកចិត្តលើក្រុមការងារបច្ចេកទេសឌីជីថលកម្រិតសាលារៀន ដើម្បីជួយដល់ការប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការបង្រៀន រៀន កម្មវិធីសិក្សា ការវាយតម្លៃ ការគ្រប់គ្រង | % បុគ្គលិករដ្ឋបាល រាយការណ៍អំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឌីជីថល |
| | # ក្រុមហ៊ុនឯកជន គ្រឹះស្ថានអប់រំ និងអង្គការសហគមន៍ គាំទ្រសាលារៀន ក្នុងការលើកកម្ពស់បរិយាកាសសិក្សាដោយប្រើធនធានឌីជីថល |
| | % អ្នកអប់រំរាយការណ៍វិជ្ជមាននិងការពេញចិត្តអំពីការទទួលបានជំនួយបច្ចេកទេស អំពីការប្រើគ្រប់គ្រងសាលារៀន ប្រព័ន្ធគ្រប់គ្រងការរៀន ផ្តល់ដោយក្រុមការងារបច្ចេកវិទ្យាឌីជីថល |
| | % អ្នកអប់រំនិងអ្នកសិក្សារាយការណ៍វិជ្ជមាននិងការពេញចិត្តអំពីការប្រើប្រព័ន្ធគ្រប់គ្រងការរៀនក្នុងដំណើរការរៀន បង្រៀន ការវាយតម្លៃការសិក្សា និងការផ្តល់មូលវិចារ |
| | # បញ្ជីធនធានសិក្សាតាមឌីជីថលសម្រាប់អ្នកអប់រំ និងសិស្ស ក្នុងទម្រង់ឥតគិតថ្លៃ |
| | # កម្មវិធីបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងធនធានសិក្សាឌីជីថលសម្រាប់គោលបំណងអប់រំ ការរៀន ការបង្រៀន និងការវាយតម្លៃការសិក្សា ចាត់ចែងដោយក្រុមការងារបច្ចេកវិទ្យាឌីជីថល |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

<table>
<tr><td colspan="2">យុទ្ធសាស្ត្រ ៥.១.៣៖ ធានាឱ្យមានភាពជាដៃគូសម្បូរបែបដើម្បីធានាសមធម៌ឌីជីថល</td></tr>
<tr><td colspan="2">លទ្ធផល ៥.១.៣.១៖ យ៉ាងហោចណាស់ពីរឆ្នាំនៃការអនុវត្ត ទំនាក់ទំនងរវាងសាលា ជាមួយសហគមន៍ មាតាបិតា និងភាគីពាក់ព័ន្ធបច្ចេកទេសឌីជីថលមានការទុកចិត្តគ្នាកម្រិតខ្ពស់</td></tr>
<tr><td rowspan="5">គំនិតផ្តួចផ្តើម១៖ បង្កើតបរិយាកាសអំណោយផលឱ្យមាតាបិតាចូលរួមជាមួយសាលារៀន ដើម្បីការរៀនរបស់កុមារ ដោយប្រើបច្ចេកវិទ្យាឌីជីថល នៅផ្ទះនិងក្នុងសាលារៀន</td><td>មានគោលការណ៍ណែនាំស្តីពីភាពជាដៃគូ រវាងសាលារៀន ជាមួយមាតាបិតា និងសហគមន៍ ដើម្បីលើកកម្ពស់ការរៀនរបស់កុមារ ដោយប្រើបច្ចេកវិទ្យាឌីជីថល ទាំងនៅផ្ទះនិងក្នុងសាលារៀន</td></tr>
<tr><td># ឪពុកម្តាយរាយការណ៍វិជ្ជមាន អំពីបទពិសោធធ្វើដៃគូជាមួយអ្នកអប់រំ និងអ្នកដឹកនាំសាលារៀន ក្នុងការជួយកុមារឱ្យរៀនតាមបច្ចេកវិទ្យាឌីជីថលនៅផ្ទះ</td></tr>
<tr><td># ព្រឹត្តិការណ៍រៀបចំដោយសហគមន៍ និងមាតាបិតាសិស្ស ដើម្បីលើកកម្ពស់ការរៀន ដោយប្រើបច្ចេកវិទ្យាឌីជីថល នៅតាមផ្ទះ និងក្នុងសាលារៀន</td></tr>
<tr><td># ចំនួនគ្រួសារក្នុងប្រភេទក្រីក្រទទួលបានជំនួយធនធាន និងឧបករណ៍ឌីជីថលសម្រាប់កូនរៀន</td></tr>
<tr><td># ឪពុកម្តាយរាយការណ៍ពីសកម្មភាពគាំទ្រដល់សាលារៀនក្នុងការប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់ការរៀនរបស់សិស្សនៅតាមផ្ទះ និងនៅសាលារៀន</td></tr>
<tr><td rowspan="2">គំនិតផ្តួចផ្តើមទី២៖ បង្កបរិយាកាសអំណោយផលឱ្យដៃគូបច្ចេកទេសឌីជីថល( ទាំងឯកជន )ជួយគាំទ្រដល់ការប្រើបច្ចេកវិទ្យាឌីជីថល</td><td>មានគោលការណ៍ណែនាំកម្រិតសាលារៀន ស្តីពីកិច្ចសហការក្នុងភាពជាដៃគូ រវាងសាលារៀននិងដៃគូបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន បង្រៀន និងការគ្រប់គ្រងសាលា</td></tr>
<tr><td># ដៃគូបច្ចេកវិទ្យាឌីជីថល សហការជាមួយសាលារៀន ប្រើបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន ការបង្រៀន និងការគ្រប់គ្រងសាលារៀន</td></tr>
</table>

| | |
|---|---|
| ក្នុងការរៀន បង្រៀន និងការគ្រប់គ្រង ក្នុងសាលារៀន និងតាមផ្ទះ | % គ្រូបង្រៀននិងអ្នកអប់រំរាយការណ៍វិជ្ជមានអំពីភាពជាដៃគូរបស់សាលា ជាមួយភាគីបច្ចេកទេសប្រើបច្ចេកវិទ្យាឌីជីថល |
| | # កុមារជួបការលំបាកបានទទួលការរៀន ដោយប្រើបច្ចេកវិទ្យាឌីជីថល និងធនធានឌីជីថល |
| | $ ចំនួនថវិកាប្រមូលបានពីដៃគូ តាមចំនួនឆ្នាំ សម្រាប់លើកកម្ពស់ការប្រើបច្ចេកវិទ្យាឌីជីថល |
| គំនិតផ្តួចផ្តើមទី៣៖ ផ្តល់អំណាចដល់យន្តការចម្រុះភាគី នៅកម្រិតសាលារៀន ដើម្បីផ្តល់មូលនិធិសម្រាប់ធានាឱ្យមានសមធម៌ឌីជីថល | # ដៃគូក្នុងយន្តការចម្រុះភាគីនៅកម្រិតសាលារៀន ចូលរួមរៀបចំផែនការគាំទ្រដល់ការប្រើបច្ចេកវិទ្យាឌីជីថលក្នុងសាលារៀន |
| | $ ចំនួនថវិកាប្រចាំឆ្នាំកៀរគរពីដៃគូចម្រុះភាគី ដើម្បីគាំទ្រការតភ្ជាប់អគ្គិសនី និងអ៊ីនធឺណិត |
| | $ ថវិកាប្រចាំឆ្នាំកៀរគរពីដៃគូចម្រុះភាគី សម្រាប់ផ្តល់ជំនួយឧបករណ៍ឌីជីថល និងធនធានសិក្សាឌីជីថល សម្រាប់សិស្ស ជាពិសេសសិស្សជួបការលំបាក និងគ្រូបង្រៀន |
| | % គ្រូបង្រៀនមានឧបករណ៍ឌីជីថលប្រើ និងធនធានអប់រំឌីជីថលឥតគិតថ្លៃ ប្រព័ន្ធគ្រប់គ្រងការរៀនរបស់សិស្ស និងបណ្ណាល័យទូរនិម្មិត |
| | # អ្នកអប់រំ និងអ្នកសិក្សាប្រើប្រព័ន្ធគ្រប់គ្រងការរៀនតាមប្រព័ន្ធឌីជីថល (LMS) |
| | % អ្នកអប់រំ និងអ្នកសិក្សារាយការណ៍វិជ្ជមានអំពីស្ថានភាពនៃអគ្គិសនី និងអ៊ីនធឺណិត |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៥.២. បរិវត្តកម្មទី២៖ គ្រូបង្រៀននិងអ្នកអប់រំប្រកាន់តួនាទីជាអ្នកលើកទឹកចិត្តនិងជាអ្នកដឹកនាំ ដើម្បីបង្កើតសង្គមពុទ្ធិជន ដោយប្រើបច្ចេកវិទ្យាឌីជីថល

### យុទ្ធសាស្ត្រ៥.២.១៖ អភិវឌ្ឍសមត្ថភាព ទំនុកចិត្ត និងស្វ័យប្រសិទ្ធភាពរបស់អ្នកអប់រំឱ្យប្រើបច្ចេកវិទ្យាឌីជីថល

### លទ្ធផល ៥.២.១.១៖ យ៉ាងតិចពីរឆ្នាំនៃការអនុវត្ត សមត្ថភាពឌីជីថលរបស់គ្រូបង្រៀន ជួយបង្កើនកម្រិតលទ្ធផលសិក្សារបស់សិស្ស និងគុណផលរបស់សាលារៀន

| | |
|---|---|
| គំនិតផ្តួចផ្តើម១៖ បណ្តុះវប្បធម៌សហការបច្ចេកទេសជួយសហការី និងចែករំលែកចំណេះដឹងក្នុងសាលា | # អ្នកអប់រំជួយគាំទ្របច្ចេកទេសដល់សហការីអំពីការប្រើបច្ចេកវិទ្យាឌីជីថលបំពេញភារកិច្ច |
| | # មេរៀនបច្ចេកទេសអំពីបច្ចេកវិទ្យាឌីជីថល និងបំណិនប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់ការរៀន និងបង្រៀន មានការចែករំលែកក្នុងចំណោមអ្នកអប់រំ និងគ្រូបង្រៀន |
| | # ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និងបទពិសោធអំពីការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ការរៀន និងបង្រៀន រៀបចំក្នុងសាលារៀន និងតាមសាលារៀនផ្សេង |
| | # អ្នកជំនាញឌីជីថល ចូលរួមចែករំលែកចំណេះដឹង និងបទពិសោធជាមួយអ្នកអប់រំក្នុងសាលារៀន |
| | % អ្នកអប់រំ រាយការណ៍ពីសកម្មភាពសំខាន់ៗ ធ្វើឡើងដោយសហគមន៍វិជ្ជាជីវៈគ្រូបង្រៀន |
| | # ព្រឹត្តិការណ៍រៀបចំទៀងទាត់ ដូចជាប្រជុំ សិក្ខាសាលា រៀបចំសម្រាប់អ្នកអប់រំដើម្បីចែករំលែកឧត្តមានុវត្ត អំពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ |
| | % អ្នកអប់រំរាយការណ៍ពីសកម្មភាពទាក់ទងនឹងការជួយដឹកនាំ និងណែនាំដល់គ្រូបង្រៀនថ្មីៗ |
| គំនិតផ្តួចផ្តើមទី២៖ ពង្រឹងការអនុវត្តផែនការកម្រិតសាលារៀន ស្តីពីការលើកកម្ពស់វប្បធម៌ | % អ្នកអប់រំគាំទ្រនិងអនុវត្តផែនការកម្រិតសាលារៀន ស្តីពីការលើកកម្ពស់វប្បធម៌រៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| រៀនពេញមួយជីវិត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីសកម្មភាព និងកម្មវិធីរៀនបន្ត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| | $ ចំនួនថវិកាគាំទ្រកម្មវិធីរៀននិងអភិវឌ្ឍវិជ្ជាជីវៈ កើនឡើងតាមឆ្នាំ |
| | # អ្នកអប់រំមានផែនការរៀន និងអភិវឌ្ឍវិជ្ជាជីវៈបន្ត |
| | # អ្នកអប់រំចូលរួមរៀននិងអភិវឌ្ឍវិជ្ជាជីវៈអ្នកអប់រំ តាមទម្រង់និងប្រព័ន្ធផ្សេងៗ ដូចជា រៀនក្នុងកម្មវិធីមានថ្នាក់រៀនផ្ទាល់ និងកម្មវិធីតាមប្រព័ន្ធឌីជីថល |
| គំនិតផ្តួចផ្តើមទី៣៖ អនុវត្តកញ្ចប់ឯកសារបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលសម្រាប់អ្នកអប់រំ | # កញ្ចប់ឯកសារបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថល ប្រើក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ |
| | % អ្នកអប់រំ ចេះប្រើឧបករណ៍ឌីជីថល តាមការបង្រៀនក្នុងកញ្ចប់បណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលសម្រាប់អ្នកអប់រំ |
| | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីការប្រើចំណេះដឹងរៀនពីកញ្ចប់ធនធានបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថលសម្រាប់អ្នកអប់រំ |
| គំនិតផ្តួចផ្តើមទី៤៖ ជំរុញការប្រើគរុកោសល្យឌីជីថល ក្នុងការបង្រៀន និងរៀនក្នុងថ្នាក់ | # គ្រូបង្រៀនប្រើបច្ចេកវិទ្យាឌីជីថល និងមេរៀនឌីជីថលក្នុងថ្នាក់រៀន |
| | # គ្រូបង្រៀនរៀបចំវិធីសាស្ត្របង្រៀន ការបង្រៀន និងការវាយតម្លៃ ដោយប្រើវិធីគរុកោសល្យឌីជីថល មេរៀនឌីជីថល និងវិធីរៀនតាមលក្ខណៈបុគ្គល |
| | % អ្នកអប់រំរាយការណ៍វិជ្ជមាន អំពីការលើកទឹកចិត្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងផ្តល់ស្នាដៃវិជ្ជាជីវៈឱ្យអ្នកអប់រំដែលប្រើវិធីសាស្ត្របង្រៀនបច្ចេកវិទ្យាឌីជីថល |
| | # អ្នកអប់រំចេះប្រើគេហទំព័រ និងកម្មវិធី EdTech ក្នុងការងារ និងវិជ្ជាជីវៈបង្រៀននិងការងារ |

<table>
<tr><td rowspan="5"></td><td>% អ្នកអប់រំចេះប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់វាយតម្លៃការសិក្សា</td></tr>
<tr><td>% អ្នកអប់រំចេះរចនាខ្លឹមសារមេរៀនតាមប្រព័ន្ធឌីជីថល ដោយអនុវត្តតាមគោលការណ៍សិស្សមជ្ឈមណ្ឌល គោលបំណងនៃកម្មវិធីសិក្សា និងការវាយតម្លៃគុណផលរបស់សាលារៀន</td></tr>
<tr><td>% សិស្សរាយការណ៍វិជ្ជមានអំពីបទពិសោធរៀនបំណិនគិតកម្រិតខ្ពស់ក្នុងថ្នាក់</td></tr>
<tr><td>% សិស្សរាយការណ៍វិជ្ជមានអំពីបទពិសោធរៀនជាមួយគ្រូពូកែលើកទឹកចិត្ត</td></tr>
<tr><td>% សិស្សរាយការណ៍វិជ្ជមានអំពីបទពិសោធរៀនតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល</td></tr>
<tr><td colspan="2">៥.៣.បរិវត្តកម្មទី៣៖ នាយក/នាយិកាជាអ្នកដឹកនាំមានចក្ខុវិស័យ និងជាអ្នកស្រាយបញ្ហា ដោយប្រើវិជ្ជាឌីជីថល</td></tr>
<tr><td colspan="2">យុទ្ធសាស្ត្រ ៥.៣.១៖ លើកកម្ពស់អភិបាលកិច្ចល្អរបស់សាលារៀន ដោយប្រើបំណិន និងវិជ្ជាផ្នែកបច្ចេកវិទ្យាឌីជីថល</td></tr>
<tr><td colspan="2">លទ្ធផល ៥.៣.១.១៖ យ៉ាងតិចពីរឆ្នាំក្នុងការអនុវត្ត ការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់ប្រព័ន្ធគ្រប់គ្រងសាលារៀន លទ្ធផលសិក្សារបស់សិស្សនឹងមានភាពប្រសើរឡើង</td></tr>
<tr><td rowspan="3">គំនិតផ្តួចផ្តើមទី១៖ អនុវត្តគោលការណ៍គណនេយ្យភាពក្នុងអភិបាលកិច្ចសាលារៀន</td><td># នៃសារផ្សាយចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្ររបស់សាលារៀន គិតតាមខែ (ជួបមុខផ្ទាល់និងតាមប្រព័ន្ធឌីជីថល)</td></tr>
<tr><td>% នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសាលារៀន</td></tr>
<tr><td>% នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីអាកប្បកិរិយារបស់អ្នកដឹកនាំសាលារៀន ក្នុងការលើកកម្ពស់ការរៀនបន្ត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ គិតទាំងវិជ្ជាឌីជីថលសម្រាប់ការអប់រំ</td></tr>
</table>

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីអាកប្បកិរិយារបស់អ្នកដឹកនាំសាលារៀនអំពីសកម្មភាពលើកទឹកចិត្តដល់អ្នកអប់រំ និងអ្នកសិក្សា |
| | # មានឃ្លាំងទិន្នន័យឌីជីថលមួយគួរឱ្យទុកចិត្ត និងប្រើការបាន សម្រាប់ការសម្រេចចិត្ត |
| | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីតម្លាភាពនៃការប្រើធនធានសម្រាប់អភិបាលកិច្ចសាលារៀន |
| គំនិតផ្តួចផ្តើមទី២៖ អនុវត្តគោលការណ៍លើកទឹកចិត្ត ឱ្យមានការចូលរួមរបស់ភាគីពាក់ព័ន្ធ និងដៃគូបច្ចេកទេសឌីជីថល ក្នុងការសម្រេចចិត្ត និងការស្រាយបញ្ហា | % អ្នកអប់រំបានអនុវត្តផែនការសាលារៀន ស្តីពីការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការគ្រប់គ្រងសាលារៀន |
| | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីលទ្ធផលនៃការប្រើបច្ចេកវិទ្យាឌីជីថលក្នុងការរៀននិងបង្រៀន |
| | % នៃអ្នកអប់រំរាយការណ៍វិជ្ជមានអំពីលទ្ធផលសិក្សារបស់សិស្ស ក្រោយប្រើបច្ចេកវិទ្យាឌីជីថល |
| | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីការទទួលស្គាល់ និងឱ្យតម្លៃចំពោះវិជ្ជាជីវៈអ្នកអប់រំ និងអំពីការផ្តល់រង្វាន់លើកទឹកចិត្ត ក្នុងកម្រិតសាលារៀន |
| | % អ្នកអប់រំរាយការណ៍វិជ្ជមានអំពីដំណើរការគ្រប់គ្រងសាលារៀន ដោយប្រើបច្ចេកវិទ្យាឌីជីថល |
| | # ភាគីពាក់ព័ន្ធនិងសហគមន៍រាយការណ៍វិជ្ជមានអំពីការដឹកនាំ និងអភិបាលកិច្ចរបស់សាលារៀន |

## ៥.៤. បរិវត្តកម្មទី៤៖ កម្មវិធីសិក្សាឌីជីថល និងធនធានគរុកោសល្យឌីជីថល ជួយដល់បរិវត្តកម្មនិងនវានុវត្តន៍នៃការរៀននិងបង្រៀន

យុទ្ធសាស្ត្រ ៥.៤.១៖ ផ្តល់ធនធានសិក្សាតាមប្រព័ន្ធឌីជីថលសម្រាប់ការរៀន បង្រៀន និងការវាយតម្លៃ

លទ្ធផល ៥.៤.១.១៖ យ៉ាងតិចពីរឆ្នាំនៃការអនុវត្ត អ្នកអប់រំមានភាពស្ទាត់ជំនាញ ក្នុងការប្រើកម្មវិធីសិក្សាឌីជីថល សម្រាប់ដឹកនាំការរៀន បង្រៀន និងវាយតម្លៃ

<table>
<tr><td rowspan="8">គំនិតផ្តួចផ្តើមទី១៖ ពង្រីកសមត្ថភាពអ្នកអប់រំ អំពីការប្រើធនធានសិក្សាឌីជីថល</td><td>% អ្នកអប់រំរាយការណ៍វិជ្ជមានពីការប្រើធនធានឌីជីថលសម្រាប់ការបង្រៀន ការរៀន និងវាយតម្លៃ</td></tr>
<tr><td>% សិស្សរាយការណ៍វិជ្ជមាននិងការពេញចិត្ត អំពីធនធានឌីជីថល មានក្នុងប្រព័ន្ធគ្រប់គ្រងការរៀនសម្រាប់ឱ្យសិស្សរៀនពីបទពិសោធរៀននិងឧបាយឬវិធីរៀនតាមលក្ខណៈបុគ្គល</td></tr>
<tr><td># អ្នកអប់រំប្រើវិធីសាស្ត្របង្រៀនតាមលក្ខណៈបុគ្គល ក្នុងថ្នាក់ និងការប្រើបច្ចេកវិទ្យាឌីជីថល</td></tr>
<tr><td>% អ្នកអប់រំប្រើបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើតឯកសារវាយតម្លៃ និងវាយតម្លៃលទ្ធផលសិក្សាសិស្ស</td></tr>
<tr><td>% អ្នកអប់រំទទួលការបណ្តុះបណ្តាលអំពីការរៀបចំការវាយតម្លៃ ដោយប្រើបច្ចេកវិទ្យាឌីជីថល និងផ្តល់មូលវិចារកែលម្អឥរិយាបថ និងឧបាយឬវិធីរៀនតាមលក្ខណៈបុគ្គលរបស់សិស្ស</td></tr>
<tr><td># អ្នកអប់រំប្រើប្រព័ន្ធគ្រប់គ្រងការរៀន សម្រាប់ការវាយតម្លៃការសិក្សានិងផ្តល់មូលវិចារ</td></tr>
<tr><td>% សិស្សរាយការណ៍វិជ្ជមាននិងការពេញចិត្តអំពីការវាយតម្លៃ និងមូលវិចារកែលម្អឥរិយាបថរបស់សិស្ស ដែលគ្រូប្រើប្រព័ន្ធគ្រប់គ្រងការរៀនតាមបច្ចេកវិទ្យាឌីជីថល</td></tr>
</table>

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews